00629748

លេខ/No: D427/2/11

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស/អ.ប.ជ ១៤៥

ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គបុរេ សាធារណៈ / Public CR

ប្រភេទចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 06 / 12 / 2010
ម៉ោង (Time/Heure): 10:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**សារណាតបរបស់មេធាវីការពារក្តី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ**

| ដាក់ដោយ៖ | ផ្ញើជូន៖ | ផ្ញើជូន៖ |
|---|---|---|
| **សហមេធាវី:** | **អង្គបុរេជំនុំជម្រះ** | **សហព្រះរាជអាជ្ញា** |
| លោក ផាត់ ពៅស៊ាង | ចៅក្រម ប្រាក់ គឹមសាន ប្រធាន | លោកស្រី ជា លាង |
| លោក Diana ELLIS, QC | ចៅក្រម ហួត វុទ្ធី | លោក AndrewCAYLEY |
| | ចៅក្រម Rowan DOWING | **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាង** |
| | ចៅក្រម ន័យ ថុល | |
| | ចៅក្រម Catherine MARCHI-UHEL | |
| | ចៅក្រម ប៉ែន ពេជ្រសាលី | |

# I. សេចក្តីផ្តើម និងបណ្តឹង

១. មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ (ម្ចាស់បណ្តឹងឧទ្ធរណ៍) សូមដាក់ការឆ្លើយតបរបស់ខ្លួនទៅនឹង "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" (ចម្លើយតបរបស់ ក.ស.ព) [១]។ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ មេធាវីការពារក្តីបានដាក់ "បណ្តឹងឧទ្ធរណ៍ របស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ" (បណ្តឹង ឧទ្ធរណ៍មេធាវីការពារក្តី)[២]។

២. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ មេធាវីការពារក្តីបានដាក់សំណើសុំពន្យារកាលបរិច្ឆេទដាក់ចម្លើយតបនេះ ក្នុងករណីអង្គបុរេជំនុំជម្រះបានបដិសេធមិនបើកសវនាការផ្ទាល់មាត់ ដើម្បី ស្តាប់នូវសេចក្តីសន្និដ្ឋានស្តីពីបញ្ហានេះ [៣]។ នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០ អង្គបុរេ ជំនុំជម្រះ បានជម្រាបជូនភាគីតាមរយៈអ៊ីម៉ែលថា មេធាវីការពារក្តីនឹងមានរយៈពេលដប់ ថ្ងៃដើម្បីដាក់ការឆ្លើយតបទៅនឹងចម្លើយតបរបស់ ក.ស.ព ដែលបានដាក់នៅថ្ងៃដូចគ្នា នេះ។ បញ្ជីសំអាង ផ្លូវច្បាប់ចំពោះចម្លើយតបរបស់ ក.ស.ព ត្រូវបានដាក់នៅថ្ងៃទី២៦ខែវិច្ឆិកា ឆ្នាំ២០១០។

៣. ដោយពិចារណាថា ចម្លើយតបរបស់ ក.ស.ព គឺជាចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍ដែល បាន លើកឡើងដោយ នួន ជា អៀង សារី និងម្ចាស់បណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីនឹងឆ្លើយតប ទៅនឹងបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវី ការពារក្តីដែលជាម្ចាស់បណ្តឹងឧទ្ធរណ៍តែប៉ុណ្ណោះ និងនៅត្រង់តែចំណុចដែលចម្លើយតបរបស់ ក.ស.ព ពាក់ព័ន្ធជាមួយនឹងបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីដែលបាន ជម្រាបជូនខាងលើប៉ុណ្ណោះ។

---

[១] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ D427/2/7។ ឯកសារនេះត្រូវបានជូនដំណឹងដល់ភាគី នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១០។

[២] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ។

[៣] សំណើរបស់មេធាវីការពារ អៀង ធីរិទ្ធ សុំពន្យារពេលកំណត់ដើម្បីឆ្លើយតបចំពោះចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ លេខ D427/2/5។

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៤. ចម្លើយតបរបស់ ក.ស.ព នៅក្នុងសេចក្តីផ្តើមផ្នែក គ.១ កថាខណ្ឌ ១០ លើកឡើងថា "សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់អំពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើម្ចាស់បណ្តឹងឧទ្ធរណ៍ នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន" ហើយថា ការខកខានរបស់ម្ចាស់បណ្តឹង ឧទ្ធរណ៍ មិនបាន លើកនូវយុត្តាធិការរបស់ អ.វ.ត.ក នៅដំណាក់កាលនោះ តាមការសន្និដ្ឋាន មានន័យថា មេធាវីការពារក្តីយល់ព្រមទទួល ហើយដូច្នេះពេលវេលាក្នុង ការលើកឡើងនូវបញ្ហានោះ បានផុតរលត់ទៅហើយនាពេលនេះ[៤]។ វាត្រូវបានគេអះអាងថានេះគឺជាទឡ្ហីករណ៍ដែលមានវិការៈ។ ដីកាឃុំខ្លួនពាក់ព័ន្ធនឹងសេរីភាពរបស់ជនត្រូវចោទ។ នៅក្នុងបរិបទនៃការពិចារណាអំពីបញ្ហានោះ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានស្នើឱ្យ សម្រេចអំពីបញ្ហាទាក់ទិននឹង យុត្តាធិការទៅលើបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ និងទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ។ ប្រសិនបើនៅក្នុងទឡ្ហីករណ៍របស់ ក.ស.ព មានលក្ខណៈត្រឹមត្រូវនោះ បញ្ហានៃយុត្តាធិការ នឹងត្រូវបានសម្រេចនៅពេលបង្ហាញវត្តមានដំបូងរបស់ជនត្រូវចោទ ហើយនឹងធ្វើឱ្យអស់ប្រសិទ្ធិភាពនូវសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ចំពោះបញ្ហាយុត្តាធិការ នៅពេលដែលមានដីកាដំណោះស្រាយ។ ចម្លើយតបរបស់ ក.ស.ព មិនបានបង្ហាញនូវសេចក្តីបញ្ជាក់ណាមួយ ឡើយ នៅក្នុងដីកាឃុំខ្លួនលើម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលថាយុត្តាធិការត្រូវបានបញ្ជាក់[៥]។ មេធាវីការពារក្តីយល់ឃើញថា នៅពេលដែលបញ្ហាមិនត្រូវបានលើកឡើងនោះ មិនមានអ្វី ត្រូវ"បញ្ជាក់" ពីសហចៅក្រមស៊ើបអង្កេតឡើយ។

៥. ផ្នែក គ.២.២ នៃចម្លើយតបរបស់ ក.ស.ព លើកទឡ្ហីករណ៍ថា បណ្តឹងឧទ្ធរណ៍របស់ អៀង សារី និងម្ចាស់បណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានឡើយអនុលោមតាមវិធាន ផ្នែកក្នុង២១។ នៅត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចផ្អែក បណ្តឹងឧទ្ធរណ៍របស់ខ្លួនបានឡើយទៅលើបទបញ្ញត្តិនេះ ដែលការពារនូវសិទ្ធិក្នុងការទទួលបានការ

---

[៤] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១០ យោងទៅលើដីកាឃុំខ្លួនបណ្តោះអាសន្នលើអ្នកស្រី អៀង ធីរិទ្ធ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារ លេខ C20។ ទឡ្ហីករណ៍នេះត្រូវបានពង្រីកបន្ថែមទៀតនៅក្នុងផ្នែក គ.៣ ប៉ុន្តែមិនមានទឡ្ហីករណ៍ជាក់លាក់បន្ថែមទៀតទេ។

[៥] ចម្លើយតបរបស់ ក.ស.ព ជើងទំព័រ ២៦ គ្រាន់តែយោងទៅលើឯកសារទាំងមូលប៉ុណ្ណោះ។

ជំនុំជម្រះទោសប្រកបដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងអំឡុងដំណើរការនីតិវិធី។ ក.ស.ព មានកំហុសដែលអះអាងថា "ការបកស្រាយវិធាន២១ របស់ អៀង ធីរិទ្ធ មានន័យស្មើនឹងការស្នើសុំឱ្យអង្គបុរេជំនុំជម្រះកែប្រែវិធាននេះ" [៦]។ បញ្ហាគឺថាតើវិធាន២១ ផ្តល់នូវមូលដ្ឋានបន្ថែមនៃបណ្តឹងឧទ្ធរណ៍ ឬគ្រាន់តែជួយក្នុងការបកស្រាយការអនុវត្តវិធាន៧៤(៣)។ មេធាវីការពារក្តី មិនមានបំណងស្នើសុំឱ្យមានវិសោធនកម្មវិធានឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីយល់ឃើញថា រាល់បទបញ្ញត្តិច្បាប់ទាំងអស់គឺត្រូវមានការបកស្រាយ ហើយការបកស្រាយដែលបានលើកឡើងដោយមេធាវីការពារក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី គឺអនុលោមទៅនឹងច្បាប់យុត្តិសាស្ត្រមុនៗដែលបានមកពីអង្គបុរេជំនុំជម្រះ។ វិធាន២១ ចែងអំពីមូលដ្ឋានបន្ថែម ក្នុងការប្តឹងឧទ្ធរណ៍នៅពេលដែលអាចមានការបង្ហាញថា សិទ្ធិក្នុងការទទួលបានការជំនុំជម្រះទោសប្រកបដោយយុត្តិធម៌របស់ម្ចាស់ បណ្តឹងឧទ្ធរណ៍ត្រូវបានគេរំលោភ ហើយដូច្នេះបានធ្វើឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃដំណើរការនីតិវិធី [៧]។

៦. នៅក្នុងចម្លើយតបរបស់ខ្លួន ជាពិសេសនៅក្នុងផ្នែកដែលទាក់ទិនទៅនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ក.ស.ព បានលើកទឡ្ហីករណ៍បន្ថែម ទៀត ដោយផ្អែកទៅលើយុត្តិសាស្ត្ររបស់តុលាការ ICTY។ ឧទាហរណ៍ នៅក្នុងផ្នែក គ.២.៤ សហព្រះរាជអាជ្ញាបញ្ជាក់ថា បណ្តឹងឧទ្ធរណ៍ចំពោះនិយមន័យនៃធាតុផ្សំផ្សេងៗ នៃឧក្រិដ្ឋកម្ម ឬទម្រង់ ផ្សេងៗនៃការទទួលខុសត្រូវ គឺមិនទាក់ទងនឹងយុត្តាធិការទេ ហេតុនេះមិនអាច ទទួល យកបានឡើយ។ ក្នុងខណៈដែលមេធាវីការពារក្តីទទួលស្គាល់នូវ ជំនួយរបស់ច្បាប់ យុត្តិសាស្ត្រ នៃតុលាការដទៃទៀត គួរតែមានវិធីសាស្ត្រដ៏ប្រយ័ត្នប្រយែង មួយក្នុងការយកបទបញ្ញត្តិ និងការបក ស្រាយច្បាប់យុត្តិសាស្ត្រពីតុលាការមិនអចិន្ត្រៃយ៍នានាដែលផ្អែកលើច្បាប់កុំម៉ុនឡ(common law) មកអនុវត្តដូចគ្នានៅក្នុងបទបញ្ញត្តិដំណើរការនីតិវិធីដែលផ្អែកលើច្បាប់ស៊ីវិល(civil law)នៅ អ.វ.ត.ក។ ក.ស.ពមិនបានលើកឡើងនូវហេតុផលណា មួយឡើយថាហេតុអ្វីបានជានៅក្នុង ករណីពិសេសនេះ ច្បាប់យុត្តិសាស្ត្ររបស់តុលាការ ICTY អាចយកមកអនុវត្ត បាននៅ ក្នុងដំណើរការនីតិវិធី របស់

---

[៦] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៩។

[៧] សូមមើល អ.ប.ជ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំឲ្យរកិច្ចស៊ើបសួរ ដោយមូលហេតុ រំលោភនីតិវិធី (D264/1) ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ឯកសារ លេខ D264/2/6 កថាខណ្ឌ ១៤។

អ.វ.ត.ក បានក៏ដោយសារតែលក្ខណៈ ខុសគ្នាស្រឡះ របស់ តុលាការទាំងនេះឬយ៉ាងណា។ ប្រសិនបើតុលាការជកធាតុផ្សំ មួយចំនួនចេញពីការវាយ តម្លៃ របស់ខ្លួននៅដំណាក់កាលនេះ នោះវានឹងមិនបានបញ្ជាក់ឲ្យបានច្បាស់អំពីវិសាលភាព នៃយុត្តាធិការ របស់ អ.វ.ត.ក ឡើយ។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល តម្រូវថាបញ្ហាជាច្រើនតាមដែលអាចធ្វើទៅបានត្រូវបានដោះស្រាយនៅដំណាក់កាលមុនជំនុំជម្រះក្តី ដូច្នេះការជំនុំជម្រះក្តីអាចត្រូវបានកំណត់ទុកយ៉ាងសំខាន់សម្រាប់បញ្ហានៃអង្គសេចក្តី។

៧. ដូច្នេះ មេធាវីការពារក្តីយល់ឃើញថា បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីគឺអាចទទួល យកបាន នៅគ្រប់ទិដ្ឋភាពទាំងអស់។

## III **សេចក្តីសង្ខេបនូវទឡ្ហីករណ៍**

### ៣.១ <u>ចម្លើយតបរបស់ ក.ស.ព រំលោភទៅលើសច្ចធារណ៍នៃភាពគ្មានទោសរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍</u>

៨. ការប្រើប្រាស់ភាសាដោយធ្វេសប្រហែសនៅក្នុងចម្លើយតបរបស់ ក.ស.ព ខកខានមិនបានឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវនូវសច្ចធារណ៍នៃភាពគ្មានទោសជាសិទ្ធិដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានធានាអនុលោមតាមមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR)។ ចម្លើយតបរបស់ ក.ស.ព បញ្ជាក់ថា "អៀង ធីរិទ្ធ និង អៀង សារី អាចនឹងតម្រង់ការប្រព្រឹត្តរបស់ខ្លួនឲ្យស្របទៅនឹងច្បាប់ ក៏ប៉ុន្តែពួកគាត់មិនបានធ្វើដូច្នេះទេ។ ការពន្យារអាជ្ញាយុកាលដែលបានកើតឡើងក្រោយពីបទល្មើសដែលបានចោទប្រកាន់ទាំងនេះអស់ពេលជាច្រើនឆ្នាំនោះ មិនអាចមានអានុភាពទៅលើសេចក្តីសម្រេចចិត្តរបស់ពួកគេក្នុងការប្រព្រឹត្តអំពើព្រហ្មទណ្ឌ។ លើសពីនេះទៀត ដោយសារទំហំនៃឧក្រិដ្ឋកម្មដែលពួកគាត់ ត្រូវបានបញ្ជូនខ្លួនទៅជំនុំជម្រះ នោះវានឹងមានការសង្ស័យដ៏តិចតួចប៉ុណ្ណោះ ដែលថាការចោទប្រកាន់នេះ អាចត្រូវប្រមើលដឹងជាមុនបាន នៅពេលដែលឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត" [៨]។ លើសពីនេះទៀត ចម្លើយតបរបស់ ក.ស.ព បញ្ជាក់ថា "មិនមានការសង្ស័យអ្វីទៀតឡើយដែលថា អៀង សារី និង អៀង ធីរិទ្ធ បានដឹងគ្រប់គ្រាន់នូវអំពើឧក្រិដ្ឋកម្មនានារបស់ពួកគាត់។ អាស្រ័យហេតុនេះ តាមច្បាប់

---

[៨] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៩២។

00629753



ពួកគាត់មិនអាចត្រូវបានអនុញ្ញាតឲ្យធ្វើការជំទាស់បានទេថាពួកគាត់មិនបានដឹងថាអំពើរបស់ពួកគាត់គឺជាអំពើខុស និងមិនអាចប្រមើលមើលដឹងជាមុនបានពីលទ្ធភាពនៃការចោទប្រកាន់នោះ" [៩] ។ លើសពីនេះទៀត ចម្លើយតបរបស់ ក.ស.ព បញ្ជាក់ថា "អៀង ធីរិទ្ធ បានធ្វើការបដិសេធ ដដែលៗជាហូរហែរហូតមកដល់សព្វថ្ងៃចំពោះការចូលរួមរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា" [១០] ។ មិនមានពេលណាមួយដែលម្ចាស់បណ្ដឹងឧទ្ធរណ៍បានជំទាស់ថាអំពើទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនអាចប្រមើលដឹងជាមុនបាននោះឡើយ ដែលធ្វើឲ្យការអះអាងនេះកាន់តែមានកំហុសច្រើនឡើងថែមទៀត។

៩. នៅក្នុងកថាខណ្ឌ ១៥៩ នៃចម្លើយតបរបស់ ក.ស.ព បញ្ជាក់ថា "ជនជាប់ចោទមិនមែនជាពលរដ្ឋធម្មតា(private citizen) ដូចដែល អៀង ធីរិទ្ធ បានអះអាងទេ ប៉ុន្តែគឺជាមេដឹកនាំ និងជាតំណាងផ្លូវការរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ ដែលទទួលខុសត្រូវលើការអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានារបស់កម្ពុជា រួមទាំងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរ" ដូច្នេះបញ្ជាក់ថា ការទទួលខុសត្រូវរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ គឺជាសមាជិកម្នាក់នៃក្រុមមួយ មិនមែនជាបុគ្គលឡើយ។

១០. ការអត្ថាធិប្បាយទាំងនេះនៅក្នុងចម្លើយតបរបស់ ក.ស.ព រំលោភទៅលើសច្ចធារណ៍នៃភាពគ្មានទោសរបស់ជនត្រូវចោទ និងបង្កើតនូវបរិយាកាសដែលពិរុទ្ធភាពត្រូវបានសន្មត ដែល។

## ៣.២ ចម្លើយតបរបស់ ក.ស.ព មានលក្ខណៈមិនច្បាស់លាស់

១១. មានចំណុចជាច្រើនដែល ក.ស.ព ខកខានមិនបានកំណត់អត្តសញ្ញាណផ្នែកនានានៃបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី និងសារណាបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទដទៃទៀត ដែលកំពុងត្រូវបានលើកឡើងនោះ។ ឧទាហរណ៍ ផ្នែក គ.២.៦ និង គ.២.៧ ទំនងជាសំដៅតែ ទៅលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប៉ុណ្ណោះ ទោះបីជាកថាខណ្ឌ ៣៤ សំដៅទៅលើមូលដ្ឋាន ភាគ

---

[៩] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៩៧។

[១០] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១២៣។

ច្រើនក្នុងចំណោមមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ ទាំងអស់យ៉ាងណាក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានការជាប់ពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីពិតប្រាកដ និងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទដទៃទៀតឡើយ។

## ៣.៣ ការយល់ខុសចំពោះទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី

១២. លើសពីនេះទៀត នៅក្នុងកថាខណ្ឌ ១៧២ នៃចម្លើយតបរបស់ ក.ស.ព សហព្រះរាជអាជ្ញាបញ្ជាក់ថា "អៀង ធីរិទ្ធ និង អៀង សារី ក៏មិនបានយល់ស្របទៅនឹងសេចក្តី សន្និដ្ឋានថា ការដាក់គុក ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ ដទៃទៀតបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេលវេលាដែលពាក់ព័ន្ធ នោះឡើយ"។ នេះគឺជាការយល់ខុសចំពោះបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី។ មេធាវីការពារក្តីបានលើកឡើងចំណុចនេះទាក់ទិនទៅនឹងបទល្មើសរំលោភ,"អំពើអមនុស្សធម៌ដទៃទៀត" ហើយមិនមែនទាក់ទិនទៅនឹងប្រភេទផ្សេងៗទៀតឡើយ។ លើសពីនេះទៀត បណ្តឹងឧទ្ធរណ៍របស់ មេធាវីការពារក្តីមិនបានបញ្ជាក់ថា "អំពើអមនុស្សធម៌ដទៃទៀត" មិនមែន ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ ប៉ុន្តែលើកឡើងថា "អាពាហ៍ពិពាហ៍ដោយបង្ខំ" "អំពើហិង្សាលើផ្លូវភេទ" និង "ការបាត់ខ្លួនដោយបង្ខំ" មិនស្ថិតនៅក្នុងនិយមន័យនៃ "អំពើអមនុស្សធម៌ដទៃទៀត" ឡើយ ក្នុងអំឡុងពេលវេលាដែលពាក់ព័ន្ធ។

១៣. ការយល់ខុសស្រដៀងគ្នានេះដែរចំពោះទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី មាននៅក្នុងកថាខណ្ឌ ១៨៧ នៃចម្លើយតបរបស់ ក.ស.ព ដែលនៅក្នុងកថាខណ្ឌនោះ បញ្ជាក់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចទាមទារថា ការផ្តន្ទាទោសចំពោះការដាក់គុក ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ដទៃទៀត រំលោភលើគោលការណ៍ នីត្យានុកូលភាពឡើយ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនដែលបានធ្វើការអះអាង បែបនេះឡើយ។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីគ្រាន់តែលើកឡើងអំពីបញ្ហានៃ ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ដទៃទៀតប៉ុណ្ណោះ ពោលគឺ អាពាហ៍ពិពាហ៍ដោយបង្ខំ អំពើហិង្សាលើផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ មិនមែនអំពីការដាក់ គុក ការធ្វើទារុណកម្ម និងការជម្លៀសដោយបង្ខំ ដូចដែលចម្លើយតបរបស់ ក.ស.ព លើកឡើងនោះឡើយ។

00629755



១៤. នៅក្នុងកថាខណ្ឌ ១៧៥ នៃចម្លើយតបរបស់ ក.ស.ព សហព្រះរាជអាជ្ញាបានលើកឡើង ថា បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីបានបញ្ជាក់ថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ "នាពេលបច្ចុប្បន្ន" មិនតម្រូវឱ្យអំពើដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធនោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីបានអះអាងថា ទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់ អាវុធ គឺជាលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់ អន្តរជាតិចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ ជាថ្មីម្តងទៀត នេះគឺជាការយល់ខុសចំពោះ ទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលបញ្ជាក់យ៉ាងច្បាស់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ មេធាវីការពារក្តី។ កថាខណ្ឌ ៦០ នៃបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីបញ្ជាក់ថា និយមន័យរបស់ ស.ច.ស អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិដែលយកមកប្រើនៅក្នុងដីកាដំណោះស្រាយគឺជានិយមន័យនៃលក្ខន្តិកៈតុលាការ ICC ដែលឃ្លាតឆ្ងាយពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី មិនបានជំទាស់ថា និយមន័យនាពេលបច្ចុប្បន្ននេះរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនតម្រូវឱ្យមានទំនាក់ ទំនងជាមួយជម្លោះប្រដាប់អាវុធនោះឡើយ។ លក្ខខណ្ឌតម្រូវអំពីទំនាក់ទំនង គឺជាធាតុផ្សំ មួយនៃនិយមន័យរបស់មាត្រា ៦(គ) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ ដែល ស.ច.ស មិនបានប្រតិបត្តិតាម។ កសពបានបន្តបកស្រាយខុសបន្ថែមទៀតថាអំណះអំណាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដោយអះអាងថា "អៀង ធីរិទ្ធផ្អែកតាមការអះអាងរបស់គាត់ស្តីពីការសំអាងមិនត្រឹមត្រូវដែលថាមាន តែនិយមន័យនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃធម្មនុញ្ញរបស់តុលាការយោធាតែប៉ុណ្ណោះដែលយកមកអនុវត្តនៅក្នុងច្បាប់ទំនៀមទំម្លាប់អន្តរជាតិនៅក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យ[11]។

១៥. លើសពីនេះទៀត កថាខណ្ឌ ១៧៩ នៃចម្លើយតបរបស់ ក.ស.ព បញ្ជាក់ថា "អាស្រ័យហេតុនេះ អៀង ធីរិទ្ធ មានការភាន់ច្រឡំនៅពេលគាត់អះអាងថា មានតែធម្មនុញ្ញរបស់ តុលាការយោធាអន្តរជាតិ និង [អនុសញ្ញាស្តីពីការមិនអនុវត្តន៍អាជ្ញាយុកាលចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (CNASL)] ទេ ដែលពាក់ព័ន្ធទៅនឹងអត្ថិភាព នៃការហាមប្រាមជា លក្ខណៈទំនៀមទម្លាប់ ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះឥរិយាបថជាលក្ខណៈបុគ្គល"។ ការលើកឡើងនេះមិនត្រឹមត្រូវឡើយ។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីមិន បានអះអាង

[11] ចម្លើយតបរបស់ កសព កថាខណ្ឌ ១៧២ និង១៧៩ ។

00629756



បែបនេះឡើយ។ ប៉ុន្តែបានលើកឡើងថា ស.ច.ស បានយោងតែទៅលើធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ និង CNASL ប៉ុណ្ណោះ ដើម្បី បង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានអត្ថិភាពនៅក្នុងច្បាប់អន្តរជាតិចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ហើយថា ស.ច.ស ភាន់ច្រឡំនៅក្នុងការផ្អែកទៅលើឯកសារ ទាំងនោះ។ ឧទាហរណ៍មួយទៀតនៃការយល់ខុសចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីនៅក្នុងចម្លើយតបរបស់ ក.ស.ព មាននៅក្នុងកថាខណ្ឌ ២៣៩ ដែលក្នុងកថាខណ្ឌនោះសហព្រះរាជអាជ្ញាបញ្ជាក់ថា "អៀង សារី និង អៀង ធីរិទ្ធ បានជំទាស់នឹងការរកឃើញខាង អង្គច្បាប់នេះ ដោយលើកឡើងថាទ្រឹស្តីស្តីពី"ការទទួលខុស ត្រូវរបស់ថ្នាក់លើ" មិនអាច យកមកអនុវត្តចំពោះពួកមេដឹកនាំខាងស៊ីវិលទេ" នៅពេលដែលយោងទៅលើកថាខណ្ឌ ៩៣ នៃបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី។ បណ្តឹងឧទ្ធរណ៍របស់ មេធាវីការពារក្តី មិនបានជំទាស់ថា ទ្រឹស្តី ស្តីពីការទទួលខុសត្រូវរបស់ថ្នាក់លើមិនអាចយកមកអនុវត្តចំពោះពួកមេដឹកនាំខាងស៊ីវិលនោះឡើយ។ សេចក្តីសន្និដ្ឋានបន្ទាប់ទៀតថា "អៀង សារី និង អៀង ធីរិទ្ធ បានលើកឡើងដោយមិនត្រឹមត្រូវគ្រង់ចំណុចខាងអង្គច្បាប់នេះ" [១២] គឺជាការមិនត្រឹមត្រូវស្រដៀងគ្នាដែរ។ម្ចាស់បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់គាត់ថា "ការចែងជាបទល្មើសព្រហ្មទណ្ឌ" ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមែនជាផ្នែកនៃច្បាប់ទំនៀម ទម្លាប់អន្តរជាតិឡើយ [១៣] ហើយថា ធម្មនុញ្ញ Nuremberg មិនបានបង្កើតវិធានមួយនៃ ច្បាប់ទំនៀម ទម្លាប់អន្តរជាតិ ដែលចែងជាបទល្មើសព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ [១៤]។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានលើកឡើងថា "មានតែនិយមន័យនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិប៉ុណ្ណោះដែលអនុវត្តនៅក្នុងលក្ខន្តិកៈតុលាការ IMT មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ" [១៥] ដូចដែល ក.ស.ព បានលើកឡើងនោះឡើយ។ នេះគឺជាការយល់ខុសទៅលើទឡ្ហីករណ៍របស់ ម្ចាស់បណ្តឹងឧទ្ធរណ៍។ វាមានលក្ខណៈមិនច្បាស់ថាហេតុអ្វីបានជា ក.ស.ព បកស្រាយខុសទៅលើទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ពីព្រោះម្យ៉ាងវិញទៀត ក.ស.ព ទទួល ស្គាល់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា "ការហាមប្រាមទៅលើ

---

[១២] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២៣៩។

[១៣] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី កថាខណ្ឌ ៤៩-៥៣។

[១៤] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី កថាខណ្ឌ ៥២។

[១៥] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៧២។

00629757



ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនបានតម្រូវឱ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទេ" [១៦]។

១៦. មេធាវីការពារក្តីយល់ឃើញថា ការយល់ខុសជាច្រើនចំពោះបណ្តឹងឧទ្ធរណ៍របស់មេធាវី ការពារក្តី នាំឱ្យចម្លើយតបរបស់ ក.ស.ព ខកខានមិនបានឆ្លើយតបឱ្យមានប្រសិទ្ធភាព ចំពោះបញ្ហាដែលបាន លើកឡើងដោយមេធាវីការពារក្តី។ ដូច្នេះ ទឡ្ហីករណ៍របស់ ក.ស.ព គួរត្រូវបានបដិសេធចោល។

## ៣.៤ ការយោងទៅលើសាលក្រមឌុច មិនគ្រប់គ្រាន់ឡើយ

១៧. ក្នុងកថាខណ្ឌ ១៨៥ នៃចម្លើយតបរបស់ ក.ស.ព, សហព្រះរាជអាជ្ញាស្នើថាបច្ច័យដែល ពាក់ព័ន្ធគ្នានៃជម្លោះប្រដាប់អាវុធជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានគេកំណត់យក តាម សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីបញ្ហាទំនាក់ទំនងនៅក្នុងសាលក្រមឌុច។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន មេធាវីការពារក្តីលើកឡើង [១៧] ថា ការបញ្ជាក់ហេតុផលនេះ មិនគួរត្រូវបានអនុវត្តតាមឡើយ។ ជំនួសឱ្យការលើកឡើងថាហេតុអ្វីបានជាការបញ្ជាក់ហេតុផល របស់សាលក្រមឌុច មានលក្ខណៈត្រឹមត្រូវនោះ សហព្រះរាជអាជ្ញាគ្រាន់តែបញ្ជាក់ថា "ការយក យុត្តិសាស្ត្រ អ.វ.ត.ក ដ៏ត្រឹមត្រូវមកអនុវត្តចំពោះការ ពិចារណាអំពីបញ្ហាគតិយុត្តិដូចគ្នា ធានានូវ យុត្តិសាស្ត្រគតិយុត្តិស៊ីសង្វាក់គ្នាលើកកំពស់នូវប្រសិទ្ធភាពតុលាការ និងធ្វើឱ្យការអនុវត្តរបស់ អ.វ.ត.ក ស្របគ្នាជាមួយនឹងការអនុវត្ត របស់តុលាការអន្តរជាតិដទៃទៀត ដែលជាធម្មតាយក យុត្តិសាស្ត្រផ្ទាល់ខ្លួនមកអនុវត្ត"។ សហព្រះរាជអាជ្ញា មិនបានបង្ហាញថាហេតុអ្វីបានជាយុត្តិសាស្ត្រ ពិសេសនេះមានលក្ខណៈ ត្រឹមត្រូវ ហើយគួរតែអនុវត្តតាម ទោះបីជាមេធាវីការពារក្តីលើក ទឡ្ហីករណ៍ដ៏ច្រើនគាំទ្រ ក្នុងការបដិសេធយុត្តិសាស្ត្រនេះយ៉ាងណាក៏ដោយ។ យុត្តិសាស្ត្រដែល ត្រូវបានផ្អែកទៅលើ នេះ មិនទាន់បានឆ្លងកាត់ការពិនិត្យពិច័យពីតុលាការជាន់ខ្ពស់នៅឡើយទេ។

១៨. ហេតុផលនេះហើយដែលមេធាវីការពារក្តីយល់ឃើញថា ការយោងតែទៅលើសាលក្រម ឌុច មួយ ប៉ុណ្ណោះ គឺមិនគ្រប់គ្រាន់ឡើយក្នុងការកំណត់នូវយុត្តាធិការនៅក្នុងករណីនេះ។

---

[16] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៧២។

[១៧] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី កថាខណ្ឌ ៩៦។

## ៣.៥ ការពិភាក្សាអំពីអង្គហេតុនៃរឿងក្តី

១៩. ចម្លើយតបរបស់ ក.ស.ព បញ្ជាក់យ៉ាងត្រឹមត្រូវថា "បញ្ហាអង្គហេតុ មិនមែនជាបញ្ហាយុត្តាធិការឡើយ ហើយបញ្ហានេះជាចុងក្រោយត្រូវតែត្រូវបានដោះស្រាយនៅពេល សវនាការ"[១៨]។ ពិតណាស់មេធាវីការពារក្តីក៏បានបញ្ជាក់អំពីចំណុចនេះផងដែរនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ មេធាវីការពារក្តី [១៩] ដែលជាហេតុផលមួយក្នុងចំណោមហេតុផលជាច្រើនដែលបញ្ហាមួយចំនួនមិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ។ ទោះបីជាយ៉ាងនេះក៏ដោយ ចម្លើយតបរបស់ ក.ស.ព នៅក្នុងឱកាសជាច្រើន ផ្អែកទៅលើការ ពិចារណាអង្គហេតុ ដូចដែលអាចឃើញមាន នៅក្នុងកថាខណ្ឌ ១១០-១១៣ និងកថាខណ្ឌ១៩៥ និង ១៩៦។

២០. មេធាវីការពារក្តីយល់ឃើញថា នេះមិនមែនជាពេលវេលាសមស្របសម្រាប់ការអះអាង បញ្ជាក់អំពីអង្គហេតុឡើយ ហើយដូច្នេះមេធាវីនឹងមិនឆ្លើយតបទៅពួកគាត់ឡើយនៅដំណាក់កាលនៃដំណើរការនីតិវិធីនេះទេ។

## IV ការចោទប្រកាន់អំពីឧក្រិដ្ឋកម្មជាតិ

## ៤.១ ចម្លើយតបរបស់ ក.ស.ព មិនបានឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវី ការពារក្តី

២១. ផ្នែក ច នៃចម្លើយតបរបស់ ក.ស.ព បញ្ជាក់អំពីសេចក្តីសន្និដ្ឋានរបស់ ក.ស.ព ថា អ.វ.ត.ក គួរតែមានយុត្តាធិការលើឧក្រិដ្ឋកម្មជាតិ។ នៅក្នុងផ្នែកនេះ ក.ស.ព ធ្វើការចោទ ប្រកាន់ជាច្រើនដែលទំនងជាក្នុងការបដិសេធទឡ្ហីករណ៍ ដែលមិនត្រូវបានលើកឡើងដោយបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីឡើយ។

២២. ឧទាហរណ៍ ក្នុងកថាខណ្ឌ ៨៦ ចម្លើយតបរបស់ ក.ស.ព បញ្ជាក់ថា ការពន្យារអាជ្ញាយុកាលមិនបំពានលើគោលការណ៍នីត្យានុកូលភាពទេ ពីព្រោះថាឧក្រិដ្ឋកម្មនានាដែល អៀង ធីរិទ្ធ ត្រូវបានបញ្ជូនទៅជំនុំជម្រះនៅ អ.វ.ត.ក នោះ គឺជាឧក្រិដ្ឋកម្មដែលដូចគ្នាបេះបិទទៅនឹង ឧក្រិដ្ឋកម្មដែលធ្លាប់មានអត្ថិភាពនៅរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩។ ចម្លើយតបនេះបន្តទៀតថា "អំពើមនុស្ស

---

[១៨] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២២។

[១៩] សូមមើល ឧទាហរណ៍ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី កថាខណ្ឌ ៧២។

ឃាត អំពើទារុណកម្ម និងការវាយប្រហារលើ សាសនា មានលក្ខណៈជាឧក្រិដ្ឋកម្មបែបសកលខ្លាំងណាស់ ទាំងក្នុងយុត្តាធិការជាតិ និងយុត្តាធិការអន្តរជាតិ ដែល អៀង ធីរិទ្ធ និង អៀង សារី មិនអាចអះអាងបានទេថា ពួកគេមិនបានដឹងថាអំពើទាំងឡាយរបស់ពួកគេ មានលក្ខណៈជាអំពើព្រហ្មទណ្ឌ និងថាថ្ងៃណាមួយពួកគាត់អាចត្រូវបានគេធ្វើការចោទ ប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងនោះបានឡើយ"។ បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីមិនបានអះអាងថាម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានដឹងអំពីអត្ថិភាពនៃឧក្រិដ្ឋកម្មទាំងនោះ ដូចដែលចម្លើយតបរបស់ ក.ស.ព ស្នើឡើងដោយភាន់ច្រឡំនោះឡើយ។

២៣. ឧទាហរណ៍មួយទៀតមាននៅក្នុងកថាខណ្ឌបន្ទាប់ទី៨៧ ដែលនៅក្នុងកថាខណ្ឌនោះចម្លើយតបរបស់ ក.ស.ព លើកឡើងថា អាជ្ញាយុកាលមិនដែលចេះហួសពេលទេ ហើយដូច្នេះបញ្ហា ថាតើការត្រូវធ្វើឱ្យរស់ឡើងវិញនូវអាជ្ញាយុកាលដែលកន្លងហួស បំពានលើគោលការណ៍នីត្យានុកូលភាពឬក៏អត់នោះ គឺមិនទាក់ទងទេក្នុងការកំណត់ពីសុពលភាពនៃមាត្រា៣(ថ្មី)។ ទឡ្ហីករណ៍នេះមិនត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីឡើយ។

២៤. ជាថ្មីម្តងទៀតនៅក្នុងកថាខណ្ឌ ១២៤ ដែលនៅនៅក្នុងកថាខណ្ឌនោះការចោទប្រកាន់ បានបញ្ជាក់ថា "មិនមានភស្តុតាងបញ្ជាក់ថា អៀង សារី និង អៀង ធីរិទ្ធ បានជឿជាក់ថា អាជ្ញាយុកាលបានកន្លងផុតទៅមុនការចុះចូលរបស់ពួកគេ ឬថាពួកគេត្រូវបានប៉ះពាល់ ដោយសារការសំអាងទៅលើការផុតអាជ្ញាយុកាលនោះទេ"។ មេធាវីការពារក្តីមិនបានថ្លែងបែបនោះឡើយ។ ចម្លើយតបរបស់ ក.ស.ព បញ្ជាក់ថា "ដូច្នេះ មិនមានអ្វីដែលជាការ មិនត្រឹមត្រូវក្នុងការផ្តន្ទាទោសពួកគាត់ចំពោះការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ នោះទេ"។ ត្រង់ចំណុចនេះ ក.ស.ព កំពុងតែលើកទឡ្ហីករណ៍ថា ទោះបីជាការផ្តន្ទាទោស ម្ចាស់បណ្តឹងឧទ្ធរណ៍ចំពោះឧក្រិដ្ឋកម្មជាតិនោះប្រឆាំងនឹងច្បាប់យ៉ាងណាក៏ដោយ ក៏ការ ផ្តន្ទាទោសនេះនៅតែត្រូវបានអនុញ្ញាត ពីព្រោះវាមិនមានអ្វីដែលជាការមិនត្រឹមត្រូវនោះទេ។ ការផ្តន្ទាទោសដោយផ្អែកលើមូលដ្ឋានខុសច្បាប់ត្រូវបានហាមឃាត់ ទោះបីជា *(quod non)* មិនប៉ះពាល់ដល់ម្ចាស់បណ្តឹងឧទ្ធរណ៍ក៏ដោយ។

២៥. ដូច្នេះនៅពេលដែលចម្លើយតបរបស់ ក.ស.ព ឆ្លើយតបទៅនឹងបញ្ហាមួយចំនួនដែលមិនមានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ដោយមិនបានបញ្ជាក់ថា បញ្ហាទាំងនោះត្រូវបានលើកឡើងដោយក្រុមមេធាវីការពារក្តីដទៃទៀតប៉ុណ្ណោះ នោះចម្លើយតបរបស់ ក.ស.ព មិនបានឆ្លើយតបទៅនឹងមូលដ្ឋានមួយក្នុងចំណោមមូលដ្ឋាន មួយចំនួនដែលមេធាវីការពារក្តីបានលើក

ឡើងទាក់ទិននឹងបញ្ហានេះ។ មូលដ្ឋានទីមួយ ដែល មេធាវីការពារក្តីបានលើកឡើងនៅក្នុងផ្នែក ៣.៦ នៃបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារ ក្តី គឺថា ក.ស.ព យល់ស្របជាមួយនឹងការខកខាន របស់អង្គជំនុំជម្រះសាលាដំបូងក្នុងការមិនបានសម្រេចតាមសម្លេងភាគច្រើនស្តីអំពីការអនុវត្ត ឧក្រិដ្ឋកម្មជាតិ ដែលខ្លួនមិនបាន ប្តឹងឧទ្ធរណ៍ចំពោះចំណុចនេះនៅក្នុងសាលក្រម ឌុច[២០]។

## ៤.២ ការខកខានរបស់ប្រទេសកម្ពុជាក្នុងការមិនប្រតិបត្តិតាមកាតព្វកិច្ចអន្តរជាតិ អាច មិននាំឱ្យមានការចោទប្រកាន់ដោយខុសច្បាប់

២៦. មេធាវីការពារក្តីយល់ឃើញទៀតថា ខ្លឹមសារនៃចម្លើយតបរបស់ ក.ស.ព ទាក់ទិនទៅនឹង បញ្ហានៃការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មជាតិ គឺមិនមានអង្គសេចក្តីឡើយ។ នៅក្នុងកថាខណ្ឌ ៨៧ ចម្លើយតបរបស់ ក.ស.ព លើកឡើងថា "ប្រទេសកម្ពុជាមានកាតព្វកិច្ចអន្តរជាតិ ដើម្បីកាត់សេចក្តី [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរ លើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានលើអនុសញ្ញាស្តីពីការធ្វើទារុណកម្ម] សូម្បីតែនៅពេលដែលអាជ្ញាយុកាលមួយមានបំណងចង់រារាំងដល់ការកាត់សេចក្តីទាំង នោះក៏ដោយ"។ នេះគឺជាការយល់ខុស និងភាន់ច្រឡំ។ ទីមួយ ប្រទេសកម្ពុជាពិតជាមានកាតព្វកិច្ច ហើយគួរតែគោរពកាតព្វកិច្ចនេះដើម្បីធ្វើការកាត់សេចក្តីលើឧក្រិដ្ឋកម្មទាំងនេះ នៅពេលដែលមានឱកាសស្របច្បាប់អនុវត្តបែបនេះ និងមិនស្វែងរកការផ្អែកទៅលើឧក្រិដ្ឋ កម្មដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាសម្រាប់ការធ្វើយុត្តិកម្មឡើយ។ ទីពីរ ប្រសិនបើប្រទេសកម្ពុជាមានកាតព្វកិច្ចបែបនេះ ដែលមេធាវីការពារក្តីមិនបានបដិសេធនោះ ហើយខកខានមិនបានបង្ហាញនូវច្បាប់ដើម្បីសម្រួលដល់ការចោទប្រកាន់ទាំងនោះទេ ការខកខានបែបនេះមិនអាចត្រូវបានដោះស្រាយតាមរយៈការមិនអើពើចំពោះសិទ្ធិរបស់ មេធាវីការពារក្តី ដោយមិនខ្វល់អំពីអាជ្ញាយុកាលដែលមានសុពលភាពនោះឡើយ។ ចំណុច ដូចគ្នានេះ អនុវត្តចំពោះទឡ្ហីករណ៍ដែល ក.ស.ព លើកឡើងបន្ថែមទៀតនៅក្នុងកថាខណ្ឌ ៩៥ និង ៩៦ នៃចម្លើយតបរបស់ខ្លួន។

---

[២០] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី កថាខណ្ឌ ៧៤។

## ៤.៣ ប្រភពមិនគ្រប់គ្រាន់

២៧. អាជ្ញាយុកាលត្រូវបានកំណត់ដើម្បីធានាថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ត្រូវបានពិចារណា នៅក្នុងពេលវេលាមួយដ៏សមស្រប ដែលការចោទប្រកាន់មិនអាចធ្វើបានឡើយ នៅពេលដែលហួសអាជ្ញាយុកាលនោះ។ ក្នុងកថាខណ្ឌ ៨៨ និង ៨៩ នៃចម្លើយតបរបស់ ក.ស.ព សហព្រះរាជអាជ្ញា លើកឡើងដោយភាន់ច្រឡំថា "អាជ្ញាយុកាលមានលក្ខណៈ ជានីតិវិធី ហើយការពន្យារ គឺជាបញ្ហាផ្នែកនីតិវិធី" ។ ការសន្និដ្ឋាននេះ គឺផ្អែកទៅលើ សេចក្តីសម្រេចតែមួយប៉ុណ្ណោះរបស់តុលាការធម្មនុញ្ញឆែក។ មិនមានសំអាងណាផ្សេងទៀតឡើយដើម្បីគាំទ្រដល់សេចក្តីសន្និដ្ឋានដ៏ទូលំទូលាយនេះ។ មិនមានការគាំទ្រនៅក្នុងច្បាប់ប្រទេសកម្ពុជា និងច្បាប់ ឬយុត្តិសាស្ត្រប្រទេសបារាំងឡើយ។ មេធាវីការពារក្តី ជំទាស់ទៅនឹងទឡ្ហីករណ៍នេះ និងសេចក្តីសន្និដ្ឋានដែលបានធ្វើនោះ ពោលគឺអាជ្ញាយុកាល នោះគ្រាន់តែមានលក្ខណៈជានីតិវិធីប៉ុណ្ណោះ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវបានដកស្រង់ជាច្រើនលើក[២១] ។ ទោះបីជាយ៉ាងណាក៏ដោយ ការមិនមានចែងអំពីសិទ្ធិមួយនៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនមែនមានន័យថា សិទ្ធិនោះមិនមានអត្ថិភាពឡើយ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងតិចតួចបំផុតអំពីសិទ្ធិមនុស្ស។ ការអះអាងថា សិទ្ធិមនុស្សមិនមានអត្ថិភាព ពីព្រោះកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមិនបានបញ្ជាក់នោះ គឺមិនមានអង្គសេចក្តីឡើយ។

## ៤.៤ ការរើសអើង

២៨. ចម្លើយតបរបស់ ក.ស.ព បន្ថែមទៀតថា ដោយសារក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាសន្និដ្ឋានថា ច្បាប់ស្តីពី អ.វ.ត.ក ស្របតាមរដ្ឋធម្មនុញ្ញ វាមានការចងកាតព្វកិច្ចទៅលើអង្គបុរេជំនុំជម្រះ[២២] ។ ក្នុងការគាំទ្រដល់ការអះអាងនេះ ចម្លើយតបរបស់ ក.ស.ព ដកស្រង់ពីអង្គបុរេ ជំនុំជម្រះ ដែលបញ្ជាក់ថា អង្គបុរេជំនុំជម្រះ “បានសម្រេចថា អ.វ.ត.ក គឺជាស្ថាប័នមួយ ដាច់ដោយឡែក”[២៣] ។ ដូច្នេះ អង្គបុរេជំនុំជម្រះមិនអាចពិនិត្យឡើងវិញនូវសេចក្តីសម្រេច ទាំងឡាយរបស់

---

[២១] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៩០, ៩១, ៩៥។

[២២] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១០១-១០២។

[២៣] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១០១។

តុលាការក្រៅ អ.វ.ត.ក បានឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហា នៅក្នុងដៃ មិនមែនជាការស្របតាមរដ្ឋធម្មនុញ្ញនៃច្បាប់ស្តីពី អ.វ.ត.ក ដែលត្រូវបានសម្រេចដោយក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាឡើយ។ អ្វីដែលពាក់ព័ន្ធនៅត្រង់នេះ គឺថាតើសិទ្ធិស្មើភាពគ្នារបស់ម្ចាស់បណ្តឹងឧទ្ធរណ៍នៅចំពោះមុខច្បាប់ត្រូវបានរំលោភ ឬយ៉ាងណា។ ដូច្នេះ បញ្ហាត្រង់នេះ គឺជាការរំលោភសិទ្ធិមនុស្ស និងមិនមែនជាការស្របតាមរដ្ឋ ធម្មនុញ្ញនៃច្បាប់ស្តីពី អ.វ.ត.ក ឡើយ។ ការអះអាងថា ប្រសិនបើច្បាប់មួយអនុលោមតាមរដ្ឋធម្មនុញ្ញ ការអនុវត្តរបស់ច្បាប់នោះមិនរំលោភសិទ្ធិមនុស្ស គឺមិនមានអង្គសេចក្តី ឡើយ ហើយគួរតែត្រូវបានបដិសេធ។

២៩. នៅក្នុងផ្នែក ច.៤ ចម្លើយតបរបស់ ក.ស.ព បដិសេធទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលថា ការពន្យារអាជ្ញាយុកាលជាធរមាន នាំឲ្យមានការរើសអើងប្រឆាំងនឹងម្ចាស់ បណ្តឹងឧទ្ធរណ៍ និងសហជនត្រូវចោទរបស់គាត់។ ក្នុងខណៈដែលយុត្តាធិការពង្រីកទៅដល់ក្រុមទូទៅនៃអ្នកទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត និងមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហមច្បាប់ស្តីពី អ.វ.ត.ក ត្រូវបានសម្រេចសេចក្តីដោយរដ្ឋាភិបាលកម្ពុជា ហើយរដ្ឋាភិបាលដដែលនេះបានសម្រេចថាមិនមានការចាប់ខ្លួនដែលធ្វើឡើងដោយតុលាការនេះទៀតឡើយ [២៤]។ ដូច្នេះ រដ្ឋាភិបាលបានកំណត់យ៉ាងច្បាស់ក្រឡែតនូវការអនុវត្ត នៃច្បាប់ស្តីពី អ.វ.ត.ក និងបទប្បញ្ញត្តិរបស់ច្បាប់នេះដែលពន្លាតអាជ្ញាយុកាលសម្រាប់ ឧក្រិដ្ឋកម្មជាតិដល់បុគ្គលជាក់លាក់ចំនួនប្រាំរូប។ លទ្ធផលនេះនាំឲ្យមានការរើសអើងដែលមិនអាចទទួលយកបានឡើយ។ ផងដែរនៅក្នុងមូលដ្ឋាននេះ ការអនុវត្តការពន្យារអាជ្ញាយុកាល គួរត្រូវបានបដិសេធ។ ទឡ្ហីករណ៍ ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ក្នុងការគាំទ្រចំណុចនេះ គឺជាទឡ្ហីករណ៍ថ្មី ពោលគឺថា វាមិនមែនជាហានិភ័យចំពោះសង្គ្រាមស៊ីវិលឡើយ ដែលហានិភ័យចំពោះសង្គ្រាមស៊ីវិលត្រូវបានលើកឡើងដោយរដ្ឋាភិបាលនៅក្នុងឱកាសជាច្រើន ប៉ុន្តែវាជាកង្វះខាតផ្នែកហិរញ្ញវត្ថុ និងធនធានផ្សេងៗទៀត [២៥]។ ហេតុផលសម្រាប់ការធ្វើសេចក្តីសម្រេចមិនទាក់ទិនទៅនឹងបញ្ហានៃការរើសអើង ដូច្នេះម្ចាស់បណ្តឹងឧទ្ធរណ៍ទទួងរង។

---

[២៤] សូមមើល ឧទាហរណ៍ គម្រោងយុត្តិធម៌នៅកម្ពុជា (OSJI) ការជ្រៀតជ្រែកនយោបាយនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ខែកក្កដា ឆ្នាំ២០១០។

[២៥] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១២៩។

00629763



## V យុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មអន្តរជាតិ

### ៥.១ ក.ស.ព ផ្អែកដោយមិនត្រឹមត្រូវទៅលើច្បាប់ស្តីពី អ.វ.ត.ក ក្នុងការបញ្ជាក់អំពីការអនុវត្តច្បាប់អន្តរជាតិ

៣០. ក.ស.ព លើកឡើងថា "ច្បាប់ស្តីពី អ.វ.ត.ក គឺជាលក្ខន្តិកៈដែលផ្តល់ឲ្យ អ.វ.ត.ក នូវយុត្តាធិការលើបទឧក្រិដ្ឋដូចបានរៀបរាប់រួចហើយ"[២៦] ដែលអាចអនុវត្តបាននៅក្នុង ច្បាប់ជាតិ ឬច្បាប់អន្តរជាតិនៅក្នុងអំឡុងពេលពាក់ព័ន្ធនោះ[២៧]។ ក.ស.ព បញ្ជាក់បន្ថែម ទៀតថា មាត្រា ៤ មាត្រា ៥ និងមាត្រា ៦ នៃច្បាប់ស្តីពី អ.វ.ត.ក នៅពេលអានជាមួយនឹងមាត្រា ១ និងមាត្រា ២ "មិនបន្សល់ឲ្យមានចម្ងល់អ្វីពីគោលបំណងរបស់ស្ថាប័នបញ្ញត្តិ ដែលផ្តល់អំណាចឲ្យ អ.វ.ត.ក ក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើបទ ល្មើសអន្តរ ជាតិជាក់លាក់ទាំងនោះទេ ហើយថា មិនមានបុរេលក្ខខណ្ឌបន្ថែមអ្វីដែលត្រូវ ទាមទារឲ្យ មានក្នុងការអនុវត្តច្បាប់ទាំងនោះដែរ ក្រៅពីការធានាយ៉ាងណាឲ្យមានការជំនុំជម្រះក្តី ដោយយុត្តិធម៌"[២៨]។

៣១. ម្ចាស់បណ្តឹងឧទ្ធរណ៍យល់ឃើញថា ក.ស.ព ភាន់ច្រឡំក្នុងការផ្អែកទាំងស្រុងទៅលើ ច្បាប់ស្តីពី អ.វ.ត.ក នៅពេលអះអាងថា អ.វ.ត.ក មានយុត្តាធិការដើម្បីអនុវត្តច្បាប់អន្តរជាតិនៅចំពោះមុខខ្លួន។ ម្ចាស់បណ្តឹងឧទ្ធរណ៍ទទួលស្គាល់ថា ច្បាប់ស្តីពី អ.វ.ត.ក ដែលជាលក្ខន្តិកៈតុលាការ កំណត់បញ្ជាក់នូវច្បាប់ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ព្រមទាំងឧក្រិដ្ឋកម្មនានាដែលបុគ្គលទាំងឡាយអាចត្រូវបានចោទប្រកាន់ និង ផ្តន្ទាទោស។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ស្តីពី អ.វ.ត.ក មិនមែនជាឯកសារដ៏ សំខាន់បំផុតសម្រាប់សម្រេចអំពីបញ្ហានៃភាពអាចអនុវត្តបាន នៃច្បាប់អន្តរជាតិ និងបញ្ហា នៃយុត្តាធិការឡើយ។ បញ្ហាថាតើគោលបំណងរបស់ស្ថាប័នបញ្ញត្តិ ដែលផ្តល់អំណាចឲ្យ អ.វ.ត.ក ក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួនទៅលើបទល្មើសអន្តរជាតិជាក់លាក់ ឬយ៉ាង ណាទាំងនោះ គឺមិនពាក់ព័ន្ធឡើយ នៅពេលធ្វើការសម្រេចទៅលើការអនុវត្តច្បាប់នៅចំពោះមុខ អ.វ.ត.ក។ ដូច្នេះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីត យូហ្គោស្លាវី (ICTY) បានសម្រេចថា តុលាការមិនគួរ "ផ្អែកតែទៅលើការតាក់តែង លក្ខន្តិកៈ ក្នុងការបង្កើតនូវច្បាប់

---

[២៦] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៣២។

[២៧] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៣៤។

[២៨] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៣៥។

ដែលអាចអនុវត្តបានស្តីពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឡើយ"[២៩]។

៣២. ការអនុញ្ញាតឱ្យច្បាប់ស្តីពី អ.វ.ត.ក កំណត់នូវច្បាប់ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក នឹងធ្វើមោឃៈភាពចំពោះដំណោះស្រាយដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៧៤(៣)(ក)។ វិធាន ៧៤(៣)(ក)អនុញ្ញាតឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត (ស.ច.ស) "ដែលបញ្ជាក់ពីយុត្តាធិការ របស់ អ.វ.ត.ក"។ នេះអាចសន្និដ្ឋានបានថា ស.ច.ស មានសមត្ថកិច្ចក្នុងការ សម្រេចអំពី បញ្ហាយុត្តាធិការ ហើយថា អង្គបុរេជំនុំជម្រះ (អ.ប.ជ) អាចពិនិត្យសេចក្តីសម្រេចរបស់ ពួកគាត់ឡើងវិញ។ ជាលទ្ធផល ក.ស.ព ភាន់ច្រឡំលើអង្គច្បាប់នៅពេលផ្អែកតែទៅ លើច្បាប់ស្តីពី អ.វ.ត.ក នៅពេលដែលលើកឡើងថាច្បាប់អន្តរជាតិអាចអនុវត្តបាននៅ ចំពោះមុខ អ.វ.ត.ក។

៣៣. ចម្លើយតបរបស់ ក.ស.ព បញ្ជាក់បន្ថែមទៀតថា គោលបំណងរបស់ស្ថាប័នបញ្ញត្តិ ដែលផ្តល់អំណាចឱ្យ អ.វ.ត.ក ក្នុងការអនុវត្តយុត្តាធិការទៅលើបទល្មើសអន្តរជាតិជាក់លាក់ទាំងនោះ ហើយនោះគឺជាការអនុវត្តស្របច្បាប់មួយនៃអំណាចនីតិបញ្ញត្តិរបស់ រដ្ឋសភាកម្ពុជា ដែលមានលក្ខណៈស្របទៅនឹងរដ្ឋធម្មនុញ្ញ និងលិខិតុបករណ៍ស្តីពីសិទ្ធិ មនុស្សដែលអាចអនុវត្តបាន"[៣០]។ ជាថ្មីម្តងទៀត បញ្ហានៅក្នុងដៃ គឺមិនមែនជាការស្របតាមរដ្ឋធម្មនុញ្ញនៃច្បាប់ស្តីពី អ.វ.ត.ក ឡើយ។ បញ្ហាគឺថាតើ ម្ចាស់បណ្តឹងឧទ្ធរណ៍អាច ត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដោយមិនរំលោភលើគោលការណ៍មូលដ្ឋានគ្មានបទល្មើស បើគ្មានច្បាប់ចែង (*nullum crimen sine lege)* ឬយ៉ាងណា។ ទឡ្ហីករណ៍ របស់ ក.ស.ព ទៅលើការស្របតាមរដ្ឋធម្មនុញ្ញនៃច្បាប់ស្តីពី អ.វ.ត.ក គឺមិនមានអង្គសេចក្តីឡើយ ហើយគួរតែត្រូវបានបដិសេធ។

### ៥.២ __ក.ស.ព មិនបានទទួលស្គាល់គោលការណ៍នីត្យានុកូលភាពជាបុរេលក្ខខណ្ឌសម្រាប់ការអនុវត្តច្បាប់នៅចំពោះមុខ អ.វ.ត.ក__

៣៤. ក.ស.ព អះអាងថា មិនមានបុរេលក្ខខណ្ឌសម្រាប់ការអនុវត្តច្បាប់នៅចំពោះមុខ អ.វ.ត.ក ឡើយ

[២៩] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blaskic* សំណុំរឿង លេខ IT-95-14-A, សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៤១។

[៣០] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៣៥។

"ក្រៅពីការធានាយ៉ាងណាឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌"[៣១]។

៣៥. ម្ចាស់បណ្តឹងឧទ្ធរណ៍បដិសេធការអះអាងរបស់ ក.ស.ព ពីព្រោះមានបុរេលក្ខខណ្ឌជាមូលដ្ឋានមួយត្រូវបំពេញដើម្បីឱ្យច្បាប់អាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដែលជា ការគោរពចំពោះគោលការណ៍នីត្យានុកូលភាព។ ដូច្នេះ បុគ្គលម្នាក់មិនអាចត្រូវបានចោទ ប្រកាន់ ឬជំនុំជម្រះទោសនៅចំពោះមុខតុលាការបានឡើយ ប្រសិនបើច្បាប់ដែលអាច អនុវត្តបាននៅចំពោះមុខតុលាការនោះផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអំពើដែលមិនបង្កើត បានជាបទឧក្រិដ្ឋនៅក្នុងយុត្តាធិការនៅក្នុងអំឡុងពេលនៃអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នោះ។ ដូច្នេះ អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តី *Blaskic* បញ្ជាក់ថា "ក្នុងខណៈដែលលក្ខន្តិកៈតុលាការអន្តរជាតិរៀបរាប់អំពីបទល្មើសទាំងឡាយដែលតុលាការអន្តរជាតិ មានយុត្តាធិការទៅលើនោះ តុលាការអាចដាក់ការផ្តន្ទាទោសបានតែនៅពេលដែលមានការយល់ឃើញថា បទល្មើសត្រូវបានហាមឃាត់ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលដែលមានការប្រព្រឹត្តបទល្មើសនោះតែប៉ុណ្ណោះ" [៣២] ។ ជាលទ្ធផល អ.ប.ជ នឹងត្រូវតែសម្រេចទៅលើច្បាប់ដែលអាចអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក ដោយពិចារណាអំពីគោលការណ៍គ្មានបទល្មើស បើគ្មានច្បាប់ចែង (*nullum crimen sine lege*) និងមិនមែនអំពី ការធានានូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ។

## VI ស្តីអំពីលក្ខណៈនៃ អ.វ.ត.ក

៣៦. ក.ស.ព ទទួលស្គាល់ថា "អ.វ.ត.ក ជាតុលាការកូនកាត់ដែលមានលក្ខណៈអន្តរជាតិ ដែលយុត្តាធិការលើរឿងក្តីរបស់តុលាការនេះ បញ្ចូលនូវបទល្មើសនានាដែលមាននៅក្នុងច្បាប់ ជាតិ និងច្បាប់អន្តរជាតិ" ហើយអះអាងថា "លក្ខណៈ*ខុសប្លែកពីគេ* (*sui generis*) របស់ អ.វ.ត.ក [...] បដិសេធចំពោះការប្រៀបធៀបគ្នាដោយផ្ទាល់ជាមួយតុលាការជាតិ"[៣៣]។

៣៧. ដូច្នេះ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកទឡ្ហីករណ៍ថា ប្រសិនបើ អ.វ.ត.ក គឺពិតជាតុលាការកូនកាត់ដែល

---

[៣១] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៣៥។

[៣២] រឿងក្តីរដ្ឋអាជ្ញា ទល់នឹង *Blaskic* សំណុំរឿងលេខ IT-95-14-A, សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ១៤១។

[៣៣] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៤១។

មានលក្ខណៈអន្តរជាតិ ដោយមានលក្ខណៈ*ខុសប្លែកពីគេ*នោះ អ.វ.ត.ក មិនគួរត្រូវបានគេដាក់ការប្រៀបធៀបជាមួយតុលាការអន្តរជាតិដែលមានលក្ខណៈខុសគ្នា ឡើយ ពោលគឺ តុលាការមិនអចិន្ត្រៃយ៍នានា។ នៅក្នុងបញ្ហានេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍ កត់សម្គាល់ថា យុត្តិសាស្ត្រភាគច្រើន ប្រសិនបើមិនទាំងអស់ទេ ដែលត្រូវបានយោងដោយក.ស.ព នៅក្នុងចម្លើយតបរួម ចេញមកពីតុលាការ ICTY។ ក.ស.ព "បានប្រៀបធៀប" អ.វ.ត.ក ដោយភាន់ច្រឡំ និងជាច្រើនដងជាមួយនឹងតុលាការអន្តរជាតិមួយដែលមាន លក្ខណៈ និងដើមកំណើតខុសគ្នា។

## VII. ផ្នែកស្ដីពីគោលការណ៍និត្យានុកូលភាព

### ៧.១ ការបកស្រាយខុសរបស់ ក.ស.ព ទៅលើគោលការណ៍និត្យានុកូលភាព

៣៨. ក.ស.ព បានលើកទឡ្ហីករណ៍ថា៖

> ក្នុងករណីមានការកាត់សេចក្ដីជនជាប់ចោទពីបទឧក្រិដ្ឋកម្មណាមួយក្រោមច្បាប់អន្តរជាតិ
>
> គេត្រូវបានបង្ហាញ៖ ១) បទល្មើសដែលគេបានចោទនោះបានការទទួលស្គាល់តាមច្បាប់ជាតិ ឬអន្តរជាតិក្នុងពេលប្រព្រឹត្តក្នុងលក្ខណៈដែលបង្កើតឱ្យមានការទទួលខុសត្រូវជាលក្ខណៈបុគ្គល។ ២) បទល្មើសមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ដើម្បីបង្ហាញថាការ ដាក់ទណ្ឌកម្មឧក្រិដ្ឋចំពោះអំពើរបស់ជនជាប់ចោទ គឺអាចដឹងមុនបាន និង៣) ច្បាប់ដែលនាំឱ្យមានការទទួលខុសត្រូវនោះគឺអាចឱ្យជនជាប់ចោទដឹងគ្រប់គ្រាន់[34]។

៣៩. មេធាវីការពារក្ដីសូមសន្និដ្ឋានថាក្នុងការបកស្រាយគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* "ជាការចាំបាច់ដែលត្រូវកំណត់ថាតើក្នុងពេលប្រព្រឹត្ត <u>អំពើ</u> ជាមូលដ្ឋាននោះអាចផ្ដន្ទាទោសបានដែរ ឬទេ" ហើយ "ការផ្ដោតការយកចិត្តទុកដាក់ទៅលើអំពើ ពុំមែនការរៀបរាប់ជាក់ស្ដែងនៃបទល្មើសក្នុងច្បាប់ឧក្រិដ្ឋកម្មសារធាតុ គឺមានភាពពាក់ព័ន្ធជាចម្បង"[35]។ បន្ថែមពីលើនេះ "ថាវីត្រូវ

---

៣៤ ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៤៦។

៣៥ *រឿងក្ដី រដ្ឋអាជ្ញា ទល់នឹង Hadzihasanovic et al.,* សំណុំរឿងលេខ IT-01-47-PT, សាលដីកាសម្រេចលើការជំទាស់រួមទៅនឹងយុត្តាធិការ, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២, កថាខណ្ឌ៦២ (យើងបានបន្ថែមសេចក្ដីបញ្ជាក់)។

ដឹងមុនថាអំពើរបស់ខ្លួនល្មើសនឹងច្បាប់ និងការអាចដឹងថាមានច្បាប់ចែង[36]។ ក.ស.ព ពុំបានផ្តោតការយកចិត្តទុកដាក់ទៅលើ "អំពើ" ជាជាង ទៅលើ "បទល្មើស" ឡើយ។

៤០. ក.ស.ព បានអះអាងទៀតថា "គោលការណ៍និត្យានុកូលភាពក៏ពុំបានហាមឃាត់មិនឱ្យតុលាការកំណត់សម្រេចបញ្ហាណាមួយតាមរយៈការបកស្រាយ និងការបញ្ជាក់បំភ្លឺអំពីធាតុផ្សំនៃបទល្មើសណាមួយឡើយ ឬក៏ពុំបានហាមឃាត់មិនឱ្យតុលាការសំអាងលើសេចក្តីសម្រេចសមស្របណាមួយដែលបកស្រាយធាតុផ្សំជាក់លាក់ណាមួយនៃបទល្មើសឡើយ"[37]។ ក.ស.ព បានសន្និដ្ឋានទៀតថា "យុត្តិសាស្រ្តរបស់តុលាការអន្តរជាតិ [...] អាចយកមកអនុវត្តបាននៅចំពោះ អ.វ.ត.ក ដោយសារមិនមានការវិវត្តន៍ គួរឱ្យកត់សម្គាល់នៅក្នុងច្បាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ [...] និងឆ្នាំ១៩៩១ (ពេលវេលាចាប់ផ្តើមដែលតុលាការ ICTY អាចអនុវត្តយុត្តាធិការរបស់ខ្លួន"[38]។

៤១. ម្ចាស់បណ្តឹងឧទ្ធរណ៍កត់សម្គាល់ឃើញថារយៈពេល១៦ឆ្នាំ ខណ្ឌចែកថ្ងៃចាប់ផ្តើមនៃរបបខ្មែរក្រហម (ថ្ងៃចាប់ផ្តើមនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក) និងថ្ងៃបង្កើតឱ្យមានតុលាការ ICTY និងរយៈពេលយូរជាងនេះទៀត ចាប់តាំងពីតុលាការបានបង្កើតឱ្យមានយុត្តិសាស្រ្តជាលើកដំបូង។ ការសំអាងលើសេចក្តីសម្រេចនានាដែលបានចេញកាលពី ជាង២០ឆ្នាំ ក្រោយពីថ្ងៃចាប់ផ្តើមនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ពុំអាចឆ្លុះបញ្ចាំងអំពីកាលៈទេសៈផ្លូវច្បាប់នៅឆ្នាំ១៩៧៥ បានឡើយ ហើយដូច្នេះវាធ្វើឱ្យប៉ះពាល់ដល់គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* ។ ទឡ្ហីករណ៍របស់ ក.ស.ព ដែលថា ពុំមានការវិវត្តន៍គួរឱ្យកត់សម្គាល់ក្នុងច្បាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥-១៩៩១ ពុំគួរត្រូវលើកយកមកពិចារណាឡើយ ក្នុងពេលវិភាគថាតើម្ចាស់បណ្តឹងឧទ្ធរណ៍ បានទទួលការធានាតាមគោលការណ៍និត្យានុកូលភាព ដែរឬទេនោះ។ ការវិភាគដ៏ត្រឹមត្រូវដែលត្រូវធ្វើគឺថាតើ អំពើឧក្រិដ្ឋដែលគេបានចោទប្រកាន់នោះ ពិតជារំលោភលើគោលការណ៍និត្យានុកូលភាព មែន ដែរឬទេ។

---

៣៦ *រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Hadzihasanovic et al*, សំណុំរឿងលេខ IT-01-47-PT, សាលដីកាសម្រេចលើសំណើរួមរបស់មេធាវីការ ពារក្តីស្នើសុំបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំស្តីពីយុត្តាធិការ, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២, កថាខណ្ឌ៦២។

៣៧ ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៤៧។

៣៨ ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៤៧។

00629768



## ៧.២ ក.ស.ព ពុំបានបញ្ជាក់ឱ្យច្បាស់ថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមានចែងក្នុងច្បាប់ក្នុងឆ្នាំ ១៩៧៥-១៩៧៩

### *ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពុំមែនជាបទដ្ឋានដាច់ខាតឡើយ*

៤២. ក.ស.ព លើកទឡ្ហីករណ៍ថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិគឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលដែលមានសង្គ្រាមលោកលើកទីពីរបានកើតឡើងព្រមទាំងជាតំណាងបទដ្ឋានដាច់ខាតមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិផងដែរ"[39]។

៤៣. ក.ស.ព ពុំបានកំណត់ភាពខុសគ្នាជាមូលដ្ឋានចាំបាច់ណាមួយថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពុំមែនជាបទដ្ឋានដាច់ខាត ប៉ុន្តែគេបានចាត់ទុកឧក្រិដកម្មនេះថាជា "ឧក្រិដ្ឋកម្ម មួយប្រភេទ [ដែលរាប់ថាជា] ការរំលោភជាក់ស្តែងទៅលើបទដ្ឋានដាច់ខាត" [40] ។ ប្រសិនបើគេចាត់ទុកឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាជា "ការរំលោភបទដ្ឋានដាច់ខាត" ក្នុងឆ្នាំ១៩៧៥-១៩៧៩នោះគេនឹងហាមឃាត់រដ្ឋនូវភារកិច្ច និងកាតព្វកិច្ចមួយចំនួនដែលជា របស់យើងទាំងអស់គ្នា ឬក៏ "កាតព្វកិច្ចមួយចំនួនដែលចេញមកពីបទដ្ឋានដាច់ខាត" [41] ដែលតុលាការយុត្តិធម៌អន្តរជាតិបានចាត់ទុកថាជា "កាតព្វកិច្ចរបស់រដ្ឋចំពោះសហគមន៍ អន្តរជាតិទាំងមូល" [42] ។ ដូច្នេះ សកម្មភាព ឬគោលនយោបាយណាមួយរបស់រដ្ឋដែលសំ ដៅប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បង្កើតឱ្យមានការទទួលខុសត្រូវជាផ្លូវរដ្ឋ ចំពោះការរំលោភទៅលើបទដ្ឋានដាច់ខាត [43] ពោលគឺការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះពុំមែនជាលក្ខណៈបុគ្គលឡើយ។ ដូច្នេះ ទឡ្ហីករណ៍របស់ ក.ស.ព ពុំត្រឹមត្រូវ និងត្រូវបដិសេធចោល។

---

[៣៩] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៧៨។

[៤០] C. Bassiouni *Crimes Against Humanity in International Law (១៩៩៩), ទំព័រ ២១០។*

[៤១] C. Bassiouni *Crimes Against Humanity in International Law (១៩៩៩), ទំព័រ ២១១។*

[៤២] តុលាការយុត្តិធម៌អន្តរជាតិ, Barcelona Traction (សាលក្រម), ICJ ទំព‍រ ៣២ កថាខណ្ឌ ៣៣។

[៤៣] C. Bassiouni *Crimes Against Humanity in International Law (១៩៩៩), ទំព័រ ២១២។*

***ក.ស.ព ពុំបានចង្អុលបង្ហាញថា "ការរំលោភសេពសន្ថវៈ" និង "អំពើ អមនុស្សធម៌ដទៃទៀត រួមទាំងការរៀបការដោយបង្ខំ, អំពើហិង្សាផ្លូវភេទ, និងការបាត់ខ្លួនដោយបង្ខំ" ជា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ***

៤៤. ក.ស.ព អះអាងដោយឆ្កាំឆ្កងថា "ទោះបីមិនត្រូវបានកំណត់និយមន័យថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមធម្មនុញ្ញរបស់តុលាការ Nuremberg ក៏ដោយ ក៏ [...] ការរំលោភសេពសន្ថវៈ និងអំពើអមនុស្សធម៌ដទៃទៀត រួមមាន ការរៀបការដោយបង្ខំ, [...] អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មនៅក្រោមច្បាប់ទំនៀម ទម្លាប់អន្តរជាតិ និងក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក្នុងអំឡុងពេលពាក់ព័ន្ធ"[44]។

៤៥. ពាក់ព័ន្ធទៅនឹង "ការរំលោភសេពសន្ថវៈ" ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក.ស.ព គូសបញ្ជាក់ថា "អំពើរំលោភសេពសន្ថវៈ" ត្រូវបានហាមប្រាមជាយូរមកហើយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ" [45] ។ ម្ចាស់បណ្តឹងឧទ្ធរណ៍សូមអះអាងថា ពុំមែនមកពីអំពើរំលោភសេពសន្ថវៈត្រូវបានច្បាប់ទំនៀមទម្លាប់អន្តរជាតិហាមឃាត់ ទើបគេចាត់ទុកអំពើរំលោភសេពសន្ថវៈជាបទល្មើសឧក្រិដ្ឋ និងតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលឡើយ [46] ។ ដូច្នេះ ក.ស.ព ពុំបានបង្ហាញថាអំពើរំលោភសេពសន្ថវៈត្រូវបានគេចាត់ទុកថាជាបទល្មើសឧក្រិដ្ឋមួយ ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងឆ្នាំ១៩៧៥-១៩៧៩ ឡើយ។

---

[៤៤] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៨៧។

[៤៥] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៩០។

[46] សូមអានបណ្តឹងឧទ្ធរណ៍របស់មេធាវី កថាខណ្ឌ ៦១ យោងទៅនឹង រដ្ឋអាជ្ញា និង Akayesu សំណុំរឿងលេខ: ICTR-96-4-T សាលក្រមចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៦៨៧ ដល់៦៨៨ ដែលទទួលស្គាល់ "បទរំលោភសេពសន្ថវៈ" ជាបទល្មើសប្រឆាំងនឹងមនុស្សជាតិ សំរាប់លើកទីមួយហើយនៅក្នុងប្រវត្តិសាស្ត្រ ។

៤៦. ក.ស.ព ក៏បានលើកអំណះអំណាងទៀតថា អំពើរំលោភសេពសន្ថវៈត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋ នៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ហើយគេអាចស្មានដឹងមុនក្នុងឆ្នាំ១៩៧៥-១៩៧៩ ថាអំពើរំលោភសេពសន្ថវៈគឺជាអំពើឧក្រិដ្ឋមួយ[47]។ ការដែលថាអំពើ រំលោភសេពសន្ថវៈត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋមួយក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ក្នុងប្រភេទជាបទឧក្រិដ្ឋជាតិ គឺពុំពាក់ព័ន្ធឡើយ នៅពេលគេវិភាគថាតើអំពើរំលោភសេពសន្ថវៈត្រូវបានកំណត់ជាបទឧក្រិដ្ឋក្នុងប្រភេទជា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ដែរ ឬទេនោះ។ ពុំមានមូលដ្ឋានក្នុងការសន្និដ្ឋានថា ពីឆ្នាំ១៩៧៥-១៩៧៩ ចារី អាចស្មានដឹងមុនថាអាចមានការកាត់សេចក្តីពីបទរំលោភសេពសន្ថវៈ ក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិឡើយ។ ដូច្នេះតុលាការគួរច្រានចោលទឡ្ហីករណ៍របស់ ក.ស.ព។

៤៧. ក.ស.ព អះអាងទៀតថា "អំពើហិង្សាផ្លូវភេទ" គឺជាអំពើអមនុស្សធម៌មួយទៀត ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយហេតុថាអំពើនេះស្រដៀងគ្នាទៅនឹងអំពើសេពសន្ថវៈ ដែលគេបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាយូរយារណាស់មកហើយ[48]។ ម្ចាស់បណ្តឹងឧទ្ធរណ៍សូមអះអាងថាតុលាការត្រូវច្រានចោលទឡ្ហីករណ៍នេះ។ យើងពុំអាចនិយាយថាអំពើហិង្សាផ្លូវភេទ និងអំពើរំលោភសេពសន្ថវៈ មានលក្ខណៈស្រដៀងគ្នាឡើយ ដោយហេតុថាអំពើទាំងពីរនេះមានធាតុផ្សំសត្យានុម័តិ និងចេតនាឧក្រិដ្ឋ ខុសគ្នា។ ជាការពិត ប្រសិនបើអំពើទាំងពីរនេះ ស្រដៀងគ្នាមែន ស.ច.ស នឹងពុំសម្រេចចោទប្រកាន់ពីបទ "អំពើហិង្សាផ្លូវភេទ" ដាច់ដោយឡែកពីអំពើសេពសន្ថវៈ ដោយលើកយកអំពើអមនុស្សធម៌ដទៃទៀតមកធ្វើជាសំអាងឡើយ។ បន្ថែមពីលើនេះ ផ្ទុយពីអំណះអំណាងរបស់យើងវាពុំមានភាពសមហេតុផលដែលថា ប្រសិនបើអំពើរំលោភសេពសន្ថវៈគឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិអំពើហិង្សាផ្លូវភេទក៏ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ។ យើងគួរកត់សម្គាល់ថាពាក្យ"អំពើហិង្សាផ្លូវភេទ" ដែលគេអាចចាត់ទុកថាអំពើដែលក្តោបក្រសោបទាំងអំពើដែលស្រាលជាងអំពើ រំលោភសេពសន្ថវៈនោះគឺជាពាក្យដែលមានន័យទូលំទូលាយនិងកំណត់និយមន័យពុំបានច្បាស់លាស់។

---

[៤៧] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៩០។

[៤៨] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៩៣។

៤៨. ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ ក.ស.ព អះអាងថានៅមុនឆ្នាំ១៩៧៥ "មានលិខិតុបករណ៍សិទ្ធិមនុស្សជាច្រើន បានទទួលស្គាល់នូវសិទ្ធិក្នុងការរៀបការដោយមានការ ព្រមព្រៀងដោយសេរី និងពេញលេញ" ហើយ "ការរៀបការដោយបង្ខំមានភាពស្រដៀងគ្នានឹងទាសភាពផងដែរ ដែលការពិតវាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[49]។

៤៩. ក.ស.ព ពុំមានអ្វីជាការគាំទ្រដល់អំណះអំណាងរបស់ខ្លួនដែលថា ការរៀបការដោយបង្ខំ ត្រូវបានរកឃើញនៅពេលពាក់ព័ន្ធក្រោមពាក្យ "អំពើអមនុស្សធម៌ដទៃទៀត" ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដូច្នេះ តុលាការគួរច្រានចោលទឡ្ហីករណ៍នេះ។ ទីមួយ លិខិតុបករណ៍សិទ្ធិមនុស្សដែល ក.ស.ព លើកយកមកសំអាង ពុំបានទទួលស្គាល់ថាការ រៀបការដោយបង្ខំគឺជាឧក្រិដ្ឋកម្មមួយ ដែលតម្រូវឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលឡើយ។ ទីពីរ ក.ស.ព ផ្អែកមូលដ្ឋានលើអំណះអំណាងដែលថាការរៀប ការដោយបង្ខំគឺជា "អំពើអមនុស្សធម៌មួយផ្សេងទៀត" ដោយសារតែវាស្រដៀងទៅនឹង ទាសភាព។ ប្រសិនបើការរៀបការដោយបង្ខំត្រូវបានគេប្រៀបប្រដូចទៅនឹងទាសភាព ពេលនោះ ក.ស.ព អាចអះអាងថាការរៀបការដោយបង្ខំគួរត្រូវបានកាត់សេចក្តីក្នុងប្រភេទជាឧក្រិដ្ឋកម្មទាសភាព ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

៥០. នៅទីបញ្ចប់ ក.ស.ព សន្និដ្ឋានថាការបាត់ខ្លួនដោយបង្ខំគឺជា "អំពើអមនុស្សធម៌ដទៃទៀត" នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយហេតុថាអនុសញ្ញាក្រុងឡាអេ IV ទាក់ទិននឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមលើដីគោក និងអនុសញ្ញាក្រុងហ្សឺណែវ IV "បានចែងពីយន្តការក្នុងការទប់ស្កាត់ការបាត់ខ្លួនដោយបង្ខំ"[50]។ នេះមិនមែនមកពីអនុសញ្ញាអន្តរជាតិហាមឃាត់អំពើនេះ ដែលក្រោយមកអំពើនេះកា្លយជាអំពើឧក្រិដ្ឋឡើយ។ ទឡ្ហីករណ៍នេះគួរត្រូវបានតុលាការច្រានចោល ដោយហេតុថាគ្មានអនុសញ្ញាណាមួយក្នុងចំណោមអនុសញ្ញាទាំងអស់នោះបានចាត់ទុក "ការបាត់ខ្លួនដោយបង្ខំ" ថាជាឧក្រិដ្ឋកម្មអន្តរជាតិឡើយ។

៥១. ក.ស.ព លើកអំណះអំណាងទៀតថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" រួមមានបទល្មើស ដែលនៅ

---

[៤៩] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៩៥។

[៥០] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៩៧។

សេសសល់ផ្សេងៗទៀត ដែលមានបំណងចាត់ទុកអំពើនោះថាជាបទល្មើស នៅពេលដែលអំពើនោះ បំពេញតាមលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌតម្រូវនៃបទល្មើសមួយ ក្នុងចំណោមបទល្មើសជាក់លាក់ផ្សេងៗទៀតឡើយ" [51] ។ ម្ចាស់បណ្តឹងឧទ្ធរណ៍សូមអះអាងថា "ការបាត់ខ្លួនដោយបង្ខំ" ពុំមែនជា បទល្មើសដែលនៅសេសសល់ឡើយ។ "ការបាត់ខ្លួនដោយបង្ខំ" ពុំមែនជាឧក្រិដ្ឋកម្មមួយ ដែលស្ថិតនៅក្រោមអនុសញ្ញាអន្តរជាតិឡើយ ហើយច្បាប់កម្ពុជាក្នុងឆ្នាំ១៩៧៥-១៩៧៩ ក៏ពុំបានចាត់ទុកការបាត់ខ្លួនដោយបង្ខំ ថាជាឧក្រិដ្ឋកម្មដែរ។ ដូច្នេះ តុលាការគួរច្រានចោលទឡ្ហីករណ៍របស់ ក.ស.ព។

៥២. នៅចុងបញ្ចប់ ក.ស.ព សន្និដ្ឋានថា "ចំពោះការសម្រេចទៅតាមគោលការណ៍និត្យានុកូល ភាពវិញ វាមានលក្ខណៈគ្រប់គ្រាន់ដែលថាអំពើទាំងនោះត្រូវបានកំណត់ជាបទល្មើសចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទាំងនៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដោយមិនគិតដល់ការកំណត់ជាបទឧក្រិដ្ឋតាមផ្លូវច្បាប់ចំពោះអំពើទាំងនោះទេ" ហើយ "ការរៀបការដោយបង្ខំ អំពើហិង្សាផ្លូវភេទ និងការបាត់ខ្លួនដោយបង្ខំ បំពេញតាមលក្ខខណ្ឌតម្រូវនេះ [52] ។ តុលាការគួរបដិសេធយ៉ាងដាច់អហង្កាទៅលើការអះអាងនេះ ដោយហេតុថាអំណះអំណាងនេះរំលោភលើគោលការណ៍និត្យានុកូលភាព។ យោងតាមគោលការណ៍ជា មូលដ្ឋាននេះ ការកំណត់ឧក្រិដ្ឋកម្មណាមួយថាជាបទល្មើសចាំបាច់ត្រូវមានលក្ខណៈអាច ឱ្យបុគ្គលដែលត្រូវកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មនោះ ដឹងមុនបានថាអំពើរបស់ខ្លួនជាអំពើ ឧក្រិដ្ឋ និងដឹងថាមានច្បាប់ចែង។

## ៧.៣ ក.ស.ព ពុំបានបង្ហាញថាឧក្រិដ្ឋកម្មត្រូវបានកំណត់ជាបទល្មើសក្រោមច្បាប់កម្ពុជា

៥៣. ក.ស.ព អះអាងថា "ការកំណត់ពីលក្ខណៈឧក្រិដ្ឋនៅក្នុងច្បាប់ជាតិ ចំពោះអំពើដែលកើតមុនច្បាប់នោះ ផ្តល់ឱ្យនូវការជូនដំណឹងគ្រប់គ្រាន់ពីភាពខុសឆ្គង និងលក្ខណៈឧក្រិដ្ឋនៃអំពើ នោះ បើទោះជាអំពើនោះក្រោយមកត្រូវបានចោទប្រកាន់ក្រោមប្រព័ន្ធច្បាប់អន្តរជាតិណាមួយដែលតម្រូវឱ្យមានធាតុផ្សំបន្ថែមនានាដូចជាអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ឬចេតនា រើសអើងក៏ដោយ"[53]។ ក.ស.ព

[៥១] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៩៨។

[៥២] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៩៩។

[៥៣] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៤។

លើកទឡ្ហីករណ៍ទៀតថា "ក្នុងករណីបច្ចុប្បន្ន អំពើសកម្ម និងអំពើអកម្ម ដែលត្រូវបានចោទប្រកាន់ទៅលើម្ចាស់បណ្ដឹងឧទ្ធរណ៍ ក៏ត្រូវបានកំណត់ជាបទល្មើសឧក្រិដ្ឋក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដែរ កាលក្នុងអំឡុងរយៈកាលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩" ហើយ "ចំណុចនេះគាំទ្របន្ថែមដល់ការសន្និដ្ឋានថាបទល្មើសទាំងនេះ មានចែងក្នុងច្បាប់ក្នុងអំឡុងពេលពាក់ព័ន្ធ"[54]។

៥៤. ក.ស.ព យោងទៅលើមាត្រា៥០០,៥០១-៥០៨ និង ២០៩-២១០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ដែលកំណត់ជាបទឧក្រិដ្ឋនូវអំពើទារុណកម្ម,អំពើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញខាងសាសនា [55]។ យើងពុំដឹងអំពីមូលហេតុដែលនាំឲ្យ ក.ស.ព យោងទៅលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងធ្វើការសន្និដ្ឋានបែបនោះឡើយ ក្នុងពេលខ្លួនកំពុងព្យាយាមបង្ហាញថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, និងអំពើបំពារបំពានធ្ងន់ធ្ងរ តម្រូវឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គលចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ម្ចាស់បណ្ដឹងឧទ្ធរណ៍សូមរម្លឹកថាក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពុំកំណត់ជាបទឧក្រិដ្ឋនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, ឬអំពើបំពារបំពានធ្ងន់ធ្ងរឡើយ ហើយក៏ពុំដាក់ទោសទណ្ឌចំពោះការប្រព្រឹត្តិបទឧក្រិដ្ឋអន្តរជាតិណាមួយក្នុងចំណោមបទឧក្រិដ្ឋដែលបានលើកឡើងពីខាងដើម។ ជាការសមហេតុផលដែលថាម្ចាស់បណ្ដឹងឧទ្ធរណ៍ អាចត្រឹមតែរងការចោទប្រកាន់ពីបទល្មើសនានា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ប៉ុណ្ណោះ ដែលស្ថិតក្រោមអំណាចនៃរយៈកាលនៃអាជ្ញាយុកាលជានិច្ច។

## ៧.៤ ក.ស.ព ពុំបានបង្ហាញអំពីលក្ខខណ្ឌតម្រូវនៃភាពអាចដឹងមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែង

### *ពុំមានប្រភពគ្រប់គ្រាន់*

៥៥. នៅពេលវាយតម្លៃអំពីលក្ខខណ្ឌតម្រូវនៃភាពអាចដឹងមុនថាជាបទល្មើស និងភាពអាចដឹង ថាមានច្បាប់ចែងដែលចាំបាច់ត្រូវបង្ហាញឲ្យឃើញ ដើម្បីជៀសវាងការរំលោភគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង*ក.ស.ព បានរៀបរាប់ចំណុចគួរពិចារណាមួយចំនួនដែលខ្លួនយល់ថា "ពាក់ព័ន្ធ"។

---

[៥៤] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៤។

[55] ចម្លើយតបរបស់ កសព, កថាខណ្ឌ ១៥៤ លេខចំណាងជើងឯកសារ ៤០១ ។

៥៦. ក.ស.ព លើកអំណះអំណាងថា "(១) ភាពគួរឱ្យរន្ធត់ និងភាពអសីលធម៌នៃអំពើណាមួយ អាចរួមចំណែកក្នុងការច្រានចោលការអះអាងរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលអះអាងថា មិនបានដឹងពីភាពឧក្រិដ្ឋរបស់អំពើនោះ"[56]។ ដើម្បីគាំទ្រដល់អំណះអំណាងរបស់ខ្លួន ក.ស.ព បានយោងទៅលើកថាខណ្ឌ៣៤ នៃសេចក្តីសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម ក្នុងសំណុំរឿង Milutinovic ។ ប៉ុន្តែទោះជាយ៉ាងដូច្នេះក្តី កថាខណ្ឌដែល ក.ស.ព បានដកស្រង់យកមកធ្វើជាសំអាងនេះ ពុំបានគាំទ្រដល់ការយល់ឃើញរបស់ខ្លួនទេ។ ពិសេស ក.ស.ព ពុំបានបញ្ជាក់ថាគោលការណ៍ជាមូលដ្ឋាន *គ្មានបទល្មើស បើគ្មានច្បាប់ចែង* "ពិតជាបានហាមឃាត់មិនឱ្យតុលាការបង្កើតច្បាប់ថ្មី ឬបកស្រាយច្បាប់ដែលមានស្រាប់ឱ្យ លើសពីសេចក្តីបញ្ជាក់បំភ្លឺដែលគេអាចទទួលយកបាន" [57] ។ ដូច្នេះទឡ្ហីករណ៍ ក.ស.ព ខាងលើជាទឡ្ហីករណ៍មួយដែលគ្មានមូលដ្ឋានគតិយុត្តិត្រឹមត្រូវ និងផ្ទុយពីគោលការណ៍។

៥៧. ក.ស.ព បានគូសបញ្ជាក់ទៀតថា "ប្រភេទនៃអំពើឧក្រិដ្ឋដ៏គួរឱ្យស្អប់ខ្ពើម ដែលត្រូវបានប្រព្រឹត្តឡើងទាំងនេះ ពិបាកនឹងធ្វើឱ្យមនុស្សស្គាល់ហេតុផលយល់ថាអំពើដ៏យង់ឃ្នងទាំង នេះ មិនបានរំលោភច្បាប់ និងសុភាវធម៌" ហើយ "ការពិតដែលថា ប៉ុល ពត និង អៀង សារី ត្រូវបានវិនិច្ឆ័យទោសភ្លាមៗ បន្ទាប់ពីពេលដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងឆ្នាំ១៩៧៩នោះ គឺជាការបញ្ជាក់ម្តងទៀតថា ជនជាប់ចោទអាចបានដឹងមុនអំពីការ កាត់សេចក្តីចំពោះអំពើទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"[58]។

៥៨. ជាការគួរឱ្យសោកស្តាយ អំណះអំណាងនេះពុំបានទទួលស្គាល់នូវសិទ្ធិជាមូលដ្ឋានក្នុងការ សន្មតថាគ្មានទោស។ ម្ចាស់បណ្តឹងឧទ្ធរណ៍សូមឯកភាពជាមួយនឹងទស្សនៈរបស់ ក.ស.ព ត្រង់ចំណុចផ្សេងៗក្នុងចម្លើយតបរបស់ខ្លួនដែលថាពេលនេះជាពេលវេលាពុំទាន់សមស្របឡើយដែលត្រូវលើកឡើងអំពីបញ្ហានានាពាក់ព័ន្ធនឹងអង្គហេតុនៃសំណុំរឿង។ បន្ថែមពីលើនេះ ក.ស.ព ពុំពន្យល់

---

[៥៦] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៧។

[៥៧] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Milutonivoc, លេខសំណុំរឿង* IT-99-37-AR72, សាលដីកាសម្រេចលើសំណើរបស់ Dragoljub Ojdanic ជំទាស់នឹងយុត្តាធិការ-សហឧក្រិដ្ឋកម្មរួម-ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៣, កថាខណ្ឌ៣៨។

[៥៨] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៩។

ថាតើការដែល ប៉ុល ពត និង អៀង សារី បានទទួលការកាត់សេចក្តី ពីបទប្រល័យពូជសាសន៍ នៅឆ្នាំ១៩៧៩ នឹងធ្វើឱ្យម្ចាស់បណ្តឹងឧទ្ធរណ៍អាចដឹងមុនថា អាចមានការកាត់សេចក្តីចំពោះអំពើ មួយចំនួនក្នុងចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ មេធាវីការពារក្តីសូមរម្លឹកថាក្រោយថ្ងៃដួលរលំនៃ របបកម្ពុជាប្រជាធិបតេយ្យ ទើបមានសវនាការកាត់សេចក្តី ប៉ុល ពត និង អៀង សារី នៅឆ្នាំ ១៩៧៩។

៥៩. ក.ស.ព លើកយកការយល់ឃើញមួយទៀត ដែលពាក់ព័ន្ធក្នុងការវាយតម្លៃអំពីលក្ខខណ្ឌតម្រូវនៃ ភាពអាចដឹងមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងដែលមានខ្លឹម សារថា “(២) ការ ដែលថាឧក្រិដ្ឋកម្មណាមួយ ឬទម្រង់នៃការទទួលខុសត្រូវណាមួយមាន លក្ខណៈជាទំនៀមទម្លាប់ គឺជាសញ្ញាបញ្ជាក់យ៉ាងច្បាស់ថាលក្ខខណ្ឌតម្រូវនៃភាពអាចប្រមើលមើលដឹងថាជាបទឧក្រិដ្ឋ និង ភាពអាចដឹងថាមានច្បាប់ចែងនេះត្រូវបានបំពេញ ” [59]។ ទោះបីជាយ៉ាងដូច្នេះក្តី ក.ស.ព ពុំបានផ្តល់ អ្វីជាការគាំទ្រតាមផ្លូវច្បាប់ចំពោះអំណះ អំណាងនេះឡើយ [60] ។ ក្នុងទស្សនៈជំទាស់ដោយឡែក របស់ចៅក្រម Schomburg គាត់ពុំ ដែលលើកយកមកនិយាយអំពីការយល់ឃើញនេះទេ។ សេចក្តី សម្រេចស្តីពីការរួមប្រព្រឹត្តដោយប្រយោលក្នុងសំណុំរឿង *Milotinovic* បានត្រឹមតែគូសបញ្ជាក់ ក្នុងកថាខណ្ឌដែល ក.ស.ព បានដកស្រង់នោះថា ដរាបណាមានភាពច្បាស់លាស់ថាទម្រង់នៃការ ទទួលខុសត្រូវណាមួយបានមានអត្ថិភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងពេលឧក្រិដ្ឋកម្ម នោះត្រូវបានប្រព្រឹត្ត ពេលនោះការផ្តន្ទាទោសអនុលោមតាមទម្រង់នៃការទទួលខុស ត្រូវនោះចាំ បាច់ត្រូវស្របតាមគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* ។ ក.ស.ព ពុំដែលយោងទៅដល់ “ចំណុចបញ្ជាក់ដ៏ច្បាស់លាស់” នេះឡើយ។

***សមាជិកភាពរបស់កម្ពុជាក្នុងអង្គមហាសន្និបាតអង្គការសហប្រជាជាតិពុំអាចនាំឈានទៅដល់ការ***

---

[៥៩] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៧។

[៦០] ក.ស.ព យោងលើ ទស្សនៈជំទាស់ដោយឡែករបស់ចៅក្រម Schomburg ក្នុងសាលដីកា តុលាការកំពូលក្នុងរឿងក្តី *Martic*, សាលដីកា *Milutonovic* និងសាលដីកាសម្រេចលើទំនួលខុសត្រូវរបស់ថ្នាក់លើក្នុងរឿងក្តី *Hadzihasanovic* *ដែល*ពុំមានសាល ដីកាណាមួយលើកឡើងអំពីអត្ថិភាពនៃការពិចារណា “លើកទី២” ដែល ក.ស.ព បានលើកឡើង។

***កាត់សេចក្ដីដោយខុសច្បាប់ឡើយ***

៦០. ក.ស.ព បានគូសបញ្ជាក់ទៀតថា "ដោយយោងទៅតាមការកំណត់ប្រភេទបទល្មើសប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងអំពើបំពារបំពានធ្ងន់ធ្ងរលើអនុ សញ្ញាក្រុងហ្សឺណែវនៅមុនឆ្នាំ១៩៧៥ ម្ចាស់បណ្ដឹងឧទ្ធរណ៍អាចដឹងមុនថាខ្លួនអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តនៅកម្ពុជា សូម្បីតែមិនស្ថិតក្នុងជម្លោះប្រដាប់អាវុធក្ដី ហើយព័ត៌មានចាំបាច់ដល់ការសន្និដ្ឋាននេះគឺជាព័ត៌មានសាធារណៈ និងអាចឲ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ដឹងបាន"[61]។ ក្នុងការធ្វើដូច្នេះ ក.ស.ព បញ្ជាក់ថាកម្ពុជាប្រជាធិបតេយ្យ គឺជាសមាជិកនៃអង្គមហាសន្និបាតអង្គការសហប្រជាជាតិ និងបានកត់សម្គាល់អំពីលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធមួយចំនួនដែលពាក់ព័ន្ធនឹង ឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះ។ ក.ស.ព ពុំបានលើកឡើងឲ្យបានច្បាស់លាស់ថាតើលិខិតុប ករណ៍អន្តរជាតិណាមួយដែលរបបកម្ពុជាប្រជាធិបតេយ្យគួរបានដឹងឡើយ។ បន្ថែមពីលើ នេះ ក.ស.ព បានសំអាងលើការពិតដែលថា "ជនជាប់ចោទ" គឺជាមេដឹកនាំមួយរូប និងជាតំណាងផ្លូវការរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ ទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងអន្តរជាតិនានារបស់កម្ពុជា រួមទាំងអនុសញ្ញាស្ដីពីអំពើប្រល័យពូជសាសន៍ និងអំពើបំពារបំពានធ្ងន់ធ្ងរផង ដូច្នេះគាត់ "បានដឹងច្បាស់ថា អំពើមនុស្សឃាត អំពើទារុណកម្ម និងឧក្រិដ្ឋកម្ម ផ្សេងៗទៀត ដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ គឺជាអំពើល្មើសច្បាប់ដែល ខ្លួនអាចដឹងមុនថាខ្លួនអាចនឹងរងការចោទប្រកាន់"[62]។

៦១. ក.ស.ព ពុំពន្យល់កិច្ចព្រមព្រៀងអន្តរជាតិរបស់កម្ពុជាប៉ះពាល់ដល់លទ្ធភាពដឹងមុនរបស់ម្ចាស់បណ្ដឹងឧទ្ធរណ៍ថា ខ្លួននឹងដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើណាមួយ ដូចម្ដេចនោះទេ។ កិច្ចព្រមព្រៀងអន្តរជាតិរបស់កម្ពុជាពុំពាក់ព័ន្ធឡើយ នៅពេលគេវាយ តម្លៃថាតើអំពើណាមួយអាចតម្រូវឲ្យមានទំនួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ដែរ ឬយ៉ាងណានោះ។ ហើយកិច្ចព្រមព្រៀងទាំងនោះក៏ពុំពាក់ព័ន្ធដែរនៅពេលគេកំណត់ ថាតើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះ អាចឲ្យតុលាការកាត់សេចក្ដីបាននៅកម្ពុជា ដែរ ឬយ៉ាងណានោះ។

---

៦១ ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៩។

៦២ ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៩។

00629777



*ចម្លើយតបរបស់ ក.ស.ព ពិភាក្សាអំពីអង្គហេតុនៃសំណុំរឿង*

៦២. បន្ថែមពីលើការរំលោភគោលការណ៍នៃសច្ចធានៃនិរទោស ក.ស.ព ព្យាយាមសំអាងលើអង្គហេតុនៃសំណុំរឿង។ វាស្ថិតនៅលើអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២ ក្នុងការសម្រេចថាតើម្ចាស់បណ្តឹងឧទ្ធរណ៍ "បានដឹងថា" "អំពើមនុស្សឃាត អំពើទារុណកម្ម និងឧក្រិដ្ឋកម្មផ្សេងៗ" បានកំពុងកើតឡើងនៅពេលពាក់ព័ន្ធដែរ ឬយ៉ាងណា។

៦៣. ដូច្នេះ តុលាការគួរគប្បីបដិសេធទៅនឹងការសន្និដ្ឋានរបស់ ក.ស.ព ដែលថា "នៅក្រោមកាលៈទេសៈទាំងនេះ ច្បាស់ណាស់ថាលក្ខខណ្ឌតម្រូវនៃភាពអាចដឹងមុនថាអំពើណាមួយជាបទឧក្រិដ្ឋ និងភាពអាចដឹងថាមានច្បាប់ចែង ពិតជាត្រូវបានបំពេញ ហើយយុត្តាធិការរបស់ អ.វ.ត.ក ទៅលើបទឧក្រិដ្ឋអន្តរជាតិ ពិតជាស្របទៅនឹងគោលការណ៍និត្យានុកូលភាព"[63]។

## ៧.៥ ការបកស្រាយដោយពុំត្រឹមត្រូវទៅលើមាត្រា១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

៦៤. ក.ស.ព លើកអំណះអំណាងថាឧក្រិដ្ឋកម្មអន្តរជាតិខាងលើ ស្ថិតក្នុងមាត្រា១៥(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយដូច្នេះមាត្រានេះនឹងផ្តល់លទ្ធភាពឲ្យរដ្ឋមួយអាចអនុវត្តច្បាប់ណាមួយ ដែលកំណត់ជាបទឧក្រិដ្ឋនូវអំពើណាមួយដែលក្នុងពេលប្រព្រឹត្តអាចពុំមែនជាបទល្មើសឧក្រិដ្ឋជាក់លាក់ណាមួយក្រោមច្បាប់ជាតិរបស់រដ្ឋនោះ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ, ឬច្បាប់អនុសញ្ញាអន្តរជាតិ ប្រសិនបើអំពើនោះគឺជាអំពើឧក្រិដ្ឋ អនុលោមតាមគោលការណ៍ដែលបានការទទួលស្គាល់ពីសំណាក់ប្រព័ន្ធច្បាប់ធំៗក្នុងសាកលលោក"[64]។

៦៥. ម្ចាស់បណ្តឹងឧទ្ធរណ៍សូមអះអាងថា ក.ស.ព ពិតជាបកស្រាយខុសនូវមាត្រា១៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ទោះបីនៅក្នុងចម្លើយតបរួម ក.ស.ព អះអាងថាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, និងអំពើបំពារបំពានធ្ងន់ធ្ងរ គឺជា

---

[៦៣] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៥៩។

[៦៤] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៦២។

ឧក្រិដ្ឋកម្មក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់អនុសញ្ញាក្តី ក៏ពេលនេះខ្លួននៅតែអះអាងថា "អំពើ និងបទល្មើស ដែលមានរៀបរាប់ក្នុងមាត្រា៤, មាត្រា៥, និងមាត្រា៦ នៃច្បាប់ អ.វ.ត.ក និងពាក់ព័ន្ធនឹងអំពើដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ និងបញ្ជូនរឿងទៅជំនុំជម្រះ" គឺជាអំពើឧក្រិដ្ឋអនុលោមតាមគោលការណ៍ទូទៅនៃច្បាប់ ដែលសហគមន៍ប្រជាជាតិបានទទួលស្គាល់នៅឆ្នាំ១៩៧៥"[65]។

៦៦. គេអាចយកមាត្រា១៥(២) មកប្រើប្រាស់បានតែនៅពេលណាដែល "គ្មានធាតុផ្សំណាផ្សេងក្រៅពីធាតុផ្សំដែលបានបញ្ជាក់ អាចត្រូវបានទាញយកពីសន្ធិសញ្ញាអន្តរជាតិ ឬច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬពុំប្រើប្រាស់គោលការណ៍ទូទៅនៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ឬគោលការណ៍ទូទៅនៃអន្តរជាតិ..." [66] ។ ដូច្នេះ ការអះអាងរបស់ ក.ស.ព ដែលថា "ឧក្រិដ្ឋកម្មអន្តរជាតិ" គឺជា "គោលការណ៍ទូទៅ" នៅក្នុងស្មារតីនៃមាត្រា១៥(២) គឺផ្ទុយទៅនឹងការលើកឡើងកន្លងមករបស់ ក.ស.ព។ អំពើ ឬបទល្មើសពុំអាចស្របជាមួយមាត្រា១៥(១)នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឡើយ ហើយក្នុងពេលជាមួយគ្នានេះ ត្រូវបានចាត់ទុកថាជា "គោលការណ៍ទូទៅ" តាមមាត្រា១៥(២)។

៦៧. ទោះយ៉ាងណាក្តី ម្ចាស់បណ្តឹងឧទ្ធរណ៍សូមសន្និដ្ឋានថាទោះបីឧក្រិដ្ឋកម្មទាំងនោះត្រូវបាន ចាត់ទុកថាជា "គោលការណ៍ទូទៅនៃច្បាប់ដែលសហគមន៍ប្រជាជាតិបានទទួលស្គាល់" ក្តី ក៏ការយកមាត្រា១៥(២) មកអនុវត្តគឺនៅមានកម្រិត ដោយហេតុថាគេមិនត្រូវរំលោភ គោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង* ដែលជាគោលការណ៍ចាំបាច់នៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ[67]។

## VIII. ការទទួលខុសត្រូវថ្នាក់លើ

៦៨. សហព្រះរាជអាជ្ញាមានការវៃឆ្លាតក្នុងការប្រឹងប្រែងបង្កើតអត្ថិភាពនៃគោលការណ៍ការទទួល

---

[៦៥] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ១៦៤។

[៦៦] រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Furundzija, សំណុំរឿងលេខ IT-95017/1-T, សាលក្រម, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៩៨, កថាខណ្ឌ ១៧៧។

[៦៧] C. Bassiouni Crimes Against Humanity in International Law (1999), ទំព័រ ២១១។

ខុសត្រូវរបស់ថ្នាក់លើ ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មុនឆ្នាំ១៩៧៥។

៦៩. សហព្រះរាជអាជ្ញាបានលើកយកសន្ធិសញ្ញាក្រុង Versailles មកធ្វើជាសំអាង ទោះបីខ្លួនទទួលស្គាល់ថាខ្លួនពុំបានដឹងអំពីគោលការណ៍ ដែលថាថ្នាក់លើអាចត្រូវបានដាក់ឲ្យទទួល ខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ចំពោះឧក្រិដ្ឋកម្មរបស់មនុស្សក្រោមបង្គាប់របស់ពួកគេក្តី។ ហើយទោះជាសន្ធិសញ្ញានេះពិតជាបានបង្គាប់ឲ្យមានការបង្កើតតុលាការកាត់សេចក្តីមនុស្សដែលបាន "ប្រព្រឹត្ត" ពុំមែនកាត់សេចក្តីថ្នាក់លើរបស់គេចំពោះអំពើល្មើសច្បាប់ និងទំនៀមទម្លាប់សង្គ្រាមក្តី ក៏គេពុំធ្លាប់បានបង្កើតតុលាការនោះឡើងដែរ[68]។

៧០. មេធាវីការពារក្តីសូមបញ្ជាក់ជាថ្មីនូវជំហររបស់ខ្លួនថា តុលាការក្រោយសម័យសង្គ្រាមលោកលើកទី២ ពុំបានបង្កើតឲ្យមានទស្សនទាននៃទំនួលខុសត្រូវរបស់ថ្នាក់លើឡើយ។ ចម្លើយតបរបស់ ក.ស.ព សំអាងយ៉ាងខ្លាំងទៅលើសំណុំរឿង *Yamashita* ក្នុងការបញ្ជាក់អំពីការដកស្រង់ដ៏មានសារសំខាន់ពី Guenael Mettraux [69] ។ បើទោះបីជាយ៉ាង ដូច្នេះក្តី ក.ស.ព បានបកស្រាយខុសនូវទឡ្ហីករណ៍របស់ Mettraux ដោយហេតុថាក្នុងផ្នែកដែលសហព្រះរាជអាជ្ញាបានលើកយកមកសម្អាងនោះ គាត់បានលើកឡើងថាជាការ ខុសឆ្គងក្នុងការសន្មតថាក្នុងឆ្នាំ១៩៤៥ គោលការណ៍នៃទំនួលខុសត្រូវរបស់ថ្នាក់លើបង្កើត បានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយគាត់បានព្រមានទុកជាមុនថា "យុត្តិសាស្ត្ររបស់រឿងក្តី *Yamashita* លេចធ្លោនៅក្នុងប្រវត្តិនៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ក្នុងលក្ខណៈជាការព្រមានចំពោះចេតនាមិនល្អក្នុងការបង្កើតច្បាប់ដើម្បីតម្រូវទៅតាមលទ្ធផលនៃការកាត់សេចក្តីតាមការចង់បានណាមួយ" [70] ។ ក្នុងសៀវភៅមួយស្តីពី *ទម្រង់នៃការទទួលខុសត្រូវក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ* Boas និងមនុស្សឯទៀត លើកឡើងថា "យុត្តិសាស្ត្រក្នុងរឿងក្តី *Yamashita* ពុំបានធ្វើអ្វីឲ្យបានច្រើនក្នុងការកំណត់កម្រិតនៃការ គ្រប់គ្រង ដែលថ្នាក់លើត្រូវមាន ដើម្បីទទួលខុសត្រូវតាមទម្រង់

---

[៦៨] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ២១៧។

[៦៩] ចម្លើយតបរបស់ ក.ស.ព, ជើងទំព័រ៥៤៦។

[៧០] Guenael Mattraux, The Law of Command Responsibility (2009), ទំព័រ ៧-៨ ។

00629780



នៃទំនួលខុសត្រូវនេះឡើយ" [71] ។ មានប្រតិកម្ម និងប្រតិកម្មតបជាច្រើនទៅនឹងសំណុំរឿង *Yamashita* នៅក្នុងដំណើរវិវត្តន៍នៃគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ពិសេសធាតុផ្សំអត្តនោម័តិដែលជាធាតុផ្សំមួយចាំបាច់ [72] ។ Danner and Martinez លើកឡើងថែមទៀតថា "សំណុំរឿង *Yamashita* និងសំណុំផ្សេងទៀតក្រោយសម័យសង្គ្រាមលោកលើកទី២ បានទុកឱ្យលក្ខខណ្ឌតម្រូវនៃ *ចេតនាឧក្រិដ្ឋ* សម្រាប់ទំនួលខុសត្រូវរបស់ថ្នាក់លើ មានលក្ខណៈស្រពេចស្រពិល ហើយដំណើរវិវត្តន៍នៅចន្លោះទសវត្សរ៍ចុងក្រោយនេះ ពុំបានពន្យល់ឱ្យបានច្បាស់ទៅលើចំណុចស្រពេចស្រពិលនេះទេ"[73]។

៧១. ប្រភពទាក់ទងនឹងសហរដ្ឋអាមេរិកដែល ក.ស.ព បានលើកឡើងក្នុងចម្លើយតបរបស់ខ្លួន[74] ពុំផ្តល់មូលដ្ឋានចំពោះការអះអាងថាគោលការណ៍នៃទំនួលខុសត្រូវរបស់ថ្នាក់លើ បង្កើតបានជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅមុនឆ្នាំ១៩៧៥។ ប្រភពទាក់ទង នឹងសហរដ្ឋអាមេរិកនេះក៏ត្រូវបានលើកយកមកពិភាក្សាផងដែរ នៅក្នុងផ្នែកខាងលើនៃ Mettraux បើទោះបីវាជាប្រភពពាក់ព័ន្ធយ៉ាងច្បាស់ក្រឡែតក្តី ក៏ចំណុចនេះត្រូវបានដក ចេញពីចម្លើយតបរបស់ ក.ស.ព ដែរ។ Mattraux បញ្ចេញទស្សនៈយោបល់របស់ខ្លួន ទៅលើប្រភពទាក់ទងនឹងសហរដ្ឋអាមេរិកដូចខាងក្រោមនេះ៖

> ក្នុងការបដិសេធការស្នើសុំដំណោះស្រាយរបស់ Yamashita និងការឯកភាពតាមសំអាងហេតុរបស់គណៈកម្មការ តុលាការកំពូលបានប្រើប្រាស់អ្វីដែលអ្នកនិពន្ធមួយរូបហៅយ៉ាងត្រឹមត្រូវថា "ការបកស្រាយដែលស្ទើរពុំគួរឱ្យជឿជាក់បានទាល់តែសោះ អំពីវិធាននៃច្បាប់មនុស្សធម៌អន្តរជាតិ ដែល

---

៧១ Boas និង អ្នកដទៃទៀត, Forms of Responsibility in International Criminal Law (2007), ទំព័រ១៥៣។

៧២ Boas និង អ្នកដទៃទៀត, Forms of Responsibility in International Criminal Law (2007), ទំព័រ១៥៣, ដកស្រង់ចេញពី A.M. Danner និង J.S. Martinez, "Guilty Association: Joint Criminal Enterprise, Comman Responsibility, and the Development of International Criminal Law", (2005) 93 California Law Review 75, ទំព័រ ១២៥។

៧៣ A.M. Danner និង J.S. Martinez, "Guilty Association: Joint Criminal Enterprise, Comman Responsibility, and the Development of International Criminal Law", (2005) 93 California Law Review 75, ទំព័រ ១២៥។

៧៤ ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ២២០។

មានស្រាប់ ព្រមទាំងការអនុវត្តខុសនូវគោលការណ៍ទាំងនោះ ទៅលើសំណុំរឿងចំពោះមុខតុលាការ បន្ថែមពីលើការពុំអើពើទាំងស្រុងអំពីធាតុផ្សំអត្តនោម័តិចាំបាច់សម្រាប់ឧក្រិដ្ឋកម្មនោះ"។ ឥរិយាបថ ដែលថៅក្រមភាគច្រើននៃតុលាការកំពូលសហរដ្ឋអាមេរិកបានបង្កឱ្យមានការជំទាស់យ៉ាងខ្លាំងពី សំណាក់ចៅក្រមពីររូបនៃតុលាការនេះ ដែលបានបន្សល់ទុកនូវស្លាកស្នាមមិនងាយរលុបទៅដល់ ភាព ស្របច្បាប់នៃទស្សនទានទំនួលខុសត្រូវរបស់ថ្នាក់លើ និងបានចូលរួមចំណែកដល់ការធ្វើឱ្យទស្សន ទានទំនួលខុសត្រូវរបស់ថ្នាក់លើនេះ ប្រែក្លាយជាទម្រង់នៃទំនួលខុសត្រូវរបស់ថ្នាក់លើដែលមាន មូលដ្ឋានត្រឹមត្រូវ [75]។

៧២. ចំណុចនេះពុំមែនជាមូលដ្ឋានត្រឹមត្រូវក្នុងការអះអាងថា ទំនួលខុសត្រូវរបស់ថ្នាក់លើត្រូវបានគេ ទទួលស្គាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ។

៧៣. ចម្លើយតបរបស់ ក.ស.ព បានលើកយកសំណុំរឿងមួយចំនួនក្រោយសម័យសង្គ្រាមលោក លើក ទី២ មកធ្វើជាសំអាង។ សំណុំរឿងទាំងនោះពាក់ព័ន្ធនឹងថ្នាក់លើដែលគេបានចោទថា ជាអ្នក ទទួលខុសត្រូវក្នុងទម្រង់ណាមួយ ចំពោះអំពើរបស់មនុស្សក្រោមបង្គាប់របស់ខ្លួន។ សៀវភៅរបស់ Mettraux ក្រោមចំណងជើងថា *ច្បាប់នៃទំនួលខុសត្រូវរបស់ថ្នាក់លើ (The Law of Command Responsibility)* បានសរសេរថា៖

> គោលការណ៍នៃការអាចដាក់ឱ្យថ្នាក់លើឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពាក់ព័ន្ធទៅនឹងបទ ឧក្រិដ្ឋនានាដែលមនុស្សក្រោមបង្គាប់បានប្រព្រឹត្ត ត្រូវបានយកមកអនុវត្តក្នុងសំណុំរឿងមួយ
>
> ចំនួនដែលកើតចេញពីសង្គ្រាមលោកលើកទី២ ប៉ុន្តែនៅពេលចប់ការកាត់សេចក្តី "គោលការណ៍ដែលចែងពីទម្រង់នៃការទទួលខុសត្រូវរបស់[ថ្នាក់លើ] [...] [គឺ] ពុំត្រូវបានកំណត់ច្បាស់លាស់នៅឡើយទេ"[76]។

៧៤. មេធាវីការពារក្តីសូមសន្និដ្ឋានថាប្រភពទាំងប៉ុន្មានដែល ក.ស.ព បានលើកយកមកសំអាង គឺ

---

៧៥ Guenael Mattraux, The Law of Command Responsibility (2009), ទំព័រ៧-៨ (លុបចោលជើងទំព័រ)។

៧៦ Guenael Mattraux, The Law of Command Responsibility (2009), ទំព័រ១៣ (លុបចោលជើងទំព័រ), ដោយ យោងទៅលើ Law Reports of Trials of War Criminals, ជ្រើសរើស និងរៀបចំដោយគណៈកម្មការឧក្រិដ្ឋកម្មសង្គ្រាម អង្គការសហប្រជាជាតិ, វ៉ុល IV (1948), ទំព័រ ៨៥ និង ៨៧ និងយោងតាមរឿងក្តី រដ្ឋអាជ្ញា ទល់នឹង Halilovic, អង្គជំនុំជម្រះ សាលាដំបូង, សាលក្រម, លេខសំណុំរឿង IT-01-48-T, ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៥, កថាខណ្ឌ ៤២-៤៨។

ពុំទាន់គ្រប់គ្រាន់ដើម្បីបញ្ជាក់អំណះអំណាងរបស់ខ្លួនដែលថា គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើបានបង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ កាលពីពេលនោះ ឡើយ។

៧៥. ក.ស.ព បានសំអាងទៅលើពិធីសារ I នៃអនុសញ្ញាក្រុងហ្សឺណែវ ដែលទើបតែបានមានអត្ថិភាពក្នុងឆ្នាំ១៩៧៧ ប៉ុណ្ណោះ ដូចដែលបានលើកយកមកបង្ហាញក្នុងជើងទំព័រលេខ ៥៧៤ នៃចម្លើយតបរបស់ ក.ស.ព ដែលបញ្ជាក់ថាកម្ពុជាទើបតែបានចុះហត្ថលេខាលើ ពិធីសារ I នេះក្នុងឆ្នាំ១៩៩៨ ប៉ុណ្ណោះ។ ចំណុចនេះធ្វើឱ្យការពិភាក្សាអំពីលទ្ធភាពក្នុងការអនុវត្តគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់តុលាការនេះ ពុំមានភាពចាំបាច់។ ការសន្និដ្ឋានរបស់ ក.ស.ព ដែលថា "ពិធីសារបន្ថែម I ជាពិធីសារធរមាននៅកម្ពុជាមុន និងក្នុងអំឡុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ" [77] គឺពុំត្រឹមត្រូវឡើយ។ លើសពីនេះ និយមន័យនៃលក្ខខណ្ឌតម្រូវ *ចេតនាឧក្រិដ្ឋ* នៃទម្រង់នៃការទទួលខុសត្រូវនេះ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ ត្បិតសំណៅជាភាសាអង់គ្លេស និងភាសាបារាំង ជាសំណៅផ្លូវការអាចទុកចិត្តបានមែន ប៉ុន្តែសំណៅទាំងនោះពុំស្របគ្នារលូនឡើយ [78] ។ សេចក្តីអធិប្បាយរបស់ ICRC ស្តីពីចំណុចនេះពុំអាចដោះស្រាយបញ្ហាត្រង់នេះបានឡើយ ហើយនៅទីបំផុតមានតែលក្ខន្តិកៈតុលាការ ICTY និង ICTR ប៉ុណ្ណោះដែលនាំមកនូវការណែនាំត្រឹមត្រូវ[79]។

៧៦. ដូចដែល ក.ស.ព បានលើកឡើងក្នុងចម្លើយតបរបស់ខ្លួន [80] ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបដិសេធថាទស្សនទាននៃទំនួលខុសត្រូវរបស់ថ្នាក់លើ ពុំអាចត្រូវបានយកមកអនុវត្តចំពោះថ្នាក់លើដែលជាជនស៊ីវិលឡើយ។ ប៉ុន្តែបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីបានអះអាងថាដីកាដំណោះស្រាយពុំបាន

---

[៧៧] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ២៣០។

[៧៨] A.M. Danner និង J.S. Martinez, "Guilty Association: Joint Criminal Enterprise, Comman Responsibility, and the Development of International Criminal Law", (2005) 93 California Law Review 75, ទំព័រ ១២៦។

[៧៩] A.M. Danner និង J.S. Martinez, "Guilty Association: Joint Criminal Enterprise, Comman Responsibility, and the Development of International Criminal Law", (2005) 93 California Law Review 75, ទំព័រ ១២៦។

[៨០] ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ២៣៩។

00629783



បញ្ជាក់ថាម្ចាស់បណ្ដឹងឧទ្ធរណ៍ មានកាតព្វកិច្ចផ្លូវច្បាប់ក្នុងការទប់ស្កាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្មឡើយ ហើយភារកិច្ចនេះគឺជាភារកិច្ចចាំបាច់ក្នុងការបញ្ជាក់អំពីទំនួលខុសត្រូវរបស់ថ្នាក់លើដែលជាជនស៊ីវិល[81]។ ក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងទឡ្ហីករណ៍នេះឡើយ។ លើសពីនេះ ទោះបីគេប្រទះឃើញឧទាហរណ៍ផ្សេងៗក្នុងការយកទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តចំពោះបុគ្គលដែលពុំមែនជាយោធា ក៏វាគ្រាន់តែជាទស្សនទានមួយដែលចេញមកពីច្បាប់យោធាប៉ុណ្ណោះ ដែលអាចយកមកអនុវត្តបានចំពោះកាលៈទេសៈនានាដែលកើតមាន ក្នុងក្របខណ្ឌយោធា។

៧៧. ចម្លើយតបរបស់ ក.ស.ព ពាក់ព័ន្ធនឹងសេចក្ដីសន្និដ្ឋាននៃបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី ដែលថាគេពុំអាចយកទំនួលខុសត្រូវរបស់ថ្នាក់លើមកអនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានឡើយ។ ជាការគួរឱ្យកត់សម្គាល់ គ្រប់សំណុំរឿងដែល ក.ស.ព លើកយកមកសំអាងក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបញ្ហានានា ដែលបានលើកឡើងពាក់ព័ន្ធនឹង គោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើគឺពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលគេបានចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាម។ ជាមួយគ្នានេះ ចម្លើយតបរបស់ ក.ស.ព គាំទ្រដល់ទឡ្ហីករណ៍ មួយទៀតរបស់មេធាវីការពារក្ដី ដែលថាទស្សនទានទំនួលខុសត្រូវរបស់ថ្នាក់លើអាចយក មកអនុវត្តបានតែចំពោះឧក្រិដ្ឋកម្មសង្គ្រាម[82]។

៧៨. ការលើកឡើងក្នុងចម្លើយតបរបស់ ក.ស.ព ដែលថា "ការអះអាងរបស់ អៀង ធីរិទ្ធ ដែលថាគោលការណ៍ទំនួលខុសត្រូវរបស់ថ្នាក់លើ ពុំអាចយកមកអនុវត្តចំពោះឧក្រិដ្ឋកម្ម ប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ គួរត្រូវបានបដិសេធ" [ចម្លើយតបរបស់ ក.ស.ព, កថាខណ្ឌ២៥៧] គឺផ្អែកតាមសំណុំរឿងចំនួន៣របស់អាឡឺម៉ង់ នៅក្រោយសម័យសង្គ្រាមលោកលើកទី២ ដែលមានជាអាទិ៍ដូចជា Handloser និង Schroeder ("សំណុំរឿងវេជ្ជសាស្ត្រ") និង Memmenthey ("សំណុំរឿង Pohl")។ ក.ស.ព គូសបញ្ជាក់ថាមនុស្សទាំង៣នាក់នេះ បានទទួលការផ្ដន្ទាទោសពីបទទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ រឿងនេះពុំមែនជាការពិតឡើយ។

---

[៨១] បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី, កថាខណ្ឌ៩៣។

[៨២] សូមមើល បណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី, ផ្នែក ៣.៨.២។

៧៩. ជាការខុសឆ្គងដែល ក.ស.ព បានយកនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅ Nuremberg ទៅប្រៀបធៀបនឹងនិយមន័យនៅ អ.វ.ត.ក។

៨០. មាត្រា៦ (គ) នៃធម្មនុញ្ញ IMT ចែងអំពី "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ដូចខាងក្រោម៖

> ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ រួមមានជាអាទិ៍ដូចជា៖ អំពើមនុស្សឃាត, ការសម្លាប់រង្គាល, ការដាក់ជាទាសករ, ការនិរទេស, និងអំពើអមនុស្សធម៌ដទៃទៀត ដែលត្រូវបានប្រព្រឹត្តមកលើប្រជាជនស៊ីវិល នៅមុនពេល ឬអំឡុងពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ, ជាតិសាសន៍, ឬសាសនា ដើម្បីអនុវត្ត ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មណាមួយក្រោមយុត្តាធិការតុលាការ ដោយមិនគិតថាអំពើទាំងនោះល្មើស ឬមិនល្មើសច្បាប់ជាតិនៃប្រទេសនោះឡើយ។

៨១. មាត្រា ៥ នៃច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក កំណត់ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិ" ថាជា៖

[...]

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាល គឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិលដោយ មូលហេតុ ជាតិនយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឱ្យទៅជាទាសករ
- ការនិរទេស
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា
- អំពើអមនុស្សធម៌ផ្សេងៗទៀត។

៨២. ក្នុងការវិភាគយុត្តិសាស្ត្រតុលាការ Nuremberg ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ Egon Schwelb បាននិយាយថា "តាមគំនិតរបស់តុលាការ រាល់គ្រប់ឧក្រិដ្ឋកម្មទាំងអស់ ដែលមានចែងក្នុងមាត្រា៦(គ) [នៃធម្មនុញ្ញ IMT] គឺជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ លុះត្រាតែឧក្រិដ្ឋកម្មទាំងអស់នោះត្រូវបានប្រព្រឹត្ត ដើម្បីអនុវត្ត ឬ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឬ ឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ"[83]។ Schwelb សន្និដ្ឋានថា៖

> ដូច្នេះ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចមានចែងក្នុងធម្មនុញ្ញ London ពុំមែននៃប្រព័ន្ធច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ដែលអាចយកមកអនុវត្តបានដូចគ្នានៅក្នុងពេលសង្គ្រាម និងពេលសន្តិភាព ឡើយ ដោយការពារសិទ្ធិមនុស្សគ្រប់ប្រទេសទាំងអស់, ប្រជាជនស៊ីវិលទាំងឡាយ, ឲ្យរួចផុតពីកណ្តាប់ដៃមនុស្សអាក្រក់ទាំងឡាយ រួមទាំងរដ្ឋ និងរដ្ឋាភិបាលខ្លួនឯងផ្ទាល់ផង។ ដូចដែលបានបកស្រាយ ក្នុងសាលក្រមតុលាការ Nuremberg ពាក្យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានន័យចង្អៀតណាស់។ ឧក្រិដ្ឋកម្មនេះគឺជាផលសេសសល់ពីសង្គ្រាម ហើយគេអាចយកមកអនុវត្តបានតែក្នុងពេលសង្គ្រាម ឬពាក់ព័ន្ធនឹងសង្គ្រាមប៉ុណ្ណោះ ហើយវាមានគោលដៅជាចម្បងដើម្បីការពារប្រជាជននៃប្រទេសមួយទៀតឲ្យផុតពីឧក្រិដ្ឋកម្មនានា ដែលគេបានប្រព្រឹត្តឡើង ពាក់ព័ន្ធនឹងសង្គ្រាមឈ្លានពាន ពីសំណាក់រដ្ឋអំណាច និងស្ថាប័នរបស់រដ្ឋឈ្លានពាននោះ[84]។

៨៣. ដូច្នេះ និយមន័យនៃសង្គ្រាមប្រឆាំងនឹងមនុស្សជាតិ ដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក គឺខុសគ្នាទាំងស្រុងទៅនឹងនិយមន័យរបស់តុលាការ Nuremberg។ ដូច្នេះ ជាការពុំត្រឹមត្រូវដែលគេបកស្រាយទស្សនទានដូចគ្នានឹងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខតុលាការ Nuremberg និង អ.វ.ត.ក។ ចម្លើយតបរបស់ ក.ស.ព ពុំបានអើពើដល់ចំណុចនេះឡើយ។ តុលាការគួរគប្បីបដិសេធចោលដោយចាត់ទុកថាទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាគឺជាទឡ្ហីករណ៍ពុំត្រឹមត្រូវ។

## IX. សន្និដ្ឋាន

---

៨៣ Egon Schwelb "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ក្នុង៖ G. Mettraux (ed.), Perspectives on the Nuremberg Trial (2008), ទំព័រ ១៤៦។

៨៤ Egon Schwelb "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ក្នុង៖ G. Mettraux (ed.), Perspectives on the Nuremberg Trial (2008), ទំព័រ ១៤៧។

៨៤. តាមហេតុផលខាងលើ មេធាវីការពារក្តីសូមស្នើថាអង្គបុរេជំនុំជម្រះគប្បីច្រានចោលទឡ្ហីករណ៍ទាំងប៉ុន្មានដែលមាននៅក្នុងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា និងទទួលយកបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី។ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពសុំឲ្យអង្គបុរេជម្រះមេត្តា៖

- សម្រេចថាអ.វ.ត.ក ពុំមានយុត្តាធិការកាត់សេចក្តីម្ចាស់បណ្តឹងឧទ្ធរណ៍ពីបទ ឧក្រិដ្ឋមួយចំនួននិងទម្រង់នៃទំនួលខុសត្រូវដែលមានរៀបរាប់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី, ហើយនិង
- បដិសេធចោលនូវដីកាដំណោះស្រាយដោយសារកង្វះយុត្តាធិការ និងជាលទ្ធផលបានរំលោភលើសិទ្ធិក្នុងការទទួលបានការកាត់សេចក្តីដោយយុត្តិធម៌របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដូចមានរៀបរាប់ក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីរបស់ អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | រាជធានីភ្នំពេញ | [signature and stamp: AVOCAT ATTORNEY AT LAW, KINGDOM OF CAMBODIA] |